អង្គរ ជេនេរ៉ាល អ៊ិនសួរេន ម.ក
ANGKOR GENERAL INSURANCE PLC.

បណ្ណសន្យារ៉ាប់រង

ទោចក្រយានយន្ត

តារាងមាតិកា

ផ្នែកទី១៖ និយមន័យ 3
ផ្នែកទី ២៖ កម្មវត្ថុនៃការធានា 5
ផ្នែកទី ៣៖ វិសាលភាពធានារ៉ាប់រង 5
ផ្នែកទី ៤៖ អត្ថប្រយោជន៍នៃការធានា 10
ផ្នែកទី ៥៖ ការបង់បុព្វលាភធានារ៉ាប់រង 11
ផ្នែកទី ៦៖ ករណីមិនធានា 11
ផ្នែកទី ៧៖ ទីតាំងភូមិសាស្ត្រនៃការធានា 17
ផ្នែកទី ៨៖ លក្ខណៈសម្បត្តិនៃអ្នកទទួលសំណង 17
ផ្នែកទី ៩៖ ការកែប្រែកិច្ចសន្យាធានារ៉ាប់រង 17
ផ្នែកទី ១០៖ ការបន្តកិច្ចសន្យាធានារ៉ាប់រង 18
ផ្នែកទី ១១៖ ការបញ្ចប់កិច្ចសន្យាធានារ៉ាប់រង 18
ផ្នែកទី ១២៖ ការលុបចោលកិច្ចសន្យាធានារ៉ាប់រង 19
ផ្នែកទី ១៣៖ ការទាមទារសំណង 19
ផ្នែកទី ១៤៖ ការរក្សាព័ត៌មានសម្ងាត់ 21
ផ្នែកទី ១៥៖ នីតិវិធីនៃការផ្សះផ្សាវិវាទ 21
ផ្នែកទី ១៦៖ ច្បាប់និងយុត្តាធិការ 21
ផ្នែកទី ១៧៖ លក្ខខណ្ឌទូទៅ 21
ផ្នែកទី ១៨៖ នីតិវិធីប្តឹងតវ៉ា 25
ផ្នែកទី ១៩៖ ព័ត៌មានទំនាក់ទំនង 27

24/7
ទំនាក់ទំនង២៤ម៉ោង
全天候理赔团队 | 24/7 CALL CENTER
+855 78 24 24 24 / +855 87 24 24 24

អគារលេខដីឡូតិ៍C, ផ្លូវលេខ១៦៩ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
BUILDING # LAND LOT C, ST. 169, PHUM 12, SANGKAT VEAL VONG,
KHAN 7 MAKARA, PHNOM PENH, KINGDOM OF CAMBODIA.

ផ្នែកទី១៖ និយមន័យ

និយមន័យខាងក្រោមនេះអនុវត្តចំពោះកិច្ចសន្យាធានារ៉ាប់រងនេះ៖

- **គ្រឿងបន្ទាប់បន្សំ៖** សំដៅទៅលើ ឧបករណ៍ស្តង់ដារដែលភ្ជាប់ទៅលើទោចក្រយានយន្តរួមបញ្ចូលទាំង កង់ សាគួរ និងឧបករណ៍ប្រហាក់ប្រហែល ដូចបានបញ្ជាក់នៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។
- **អំពើភេរវកម្ម៖** សំដៅទៅលើ អំពើមួយដែលរួមមានជាអាទិ៍ ការប្រើប្រាស់កម្លាំងហិង្សា និង/ឬ ការគំរាមកំហែង ដោយបុគ្គលណាម្នាក់ ឬបុគ្គលជាក្រុមណាមួយ ទោះជាធ្វើឡើងម្នាក់ឯងក្តី ឬធ្វើឡើងក្នុងនាម ឬពាក់ពន្ធ័នឹងអង្គការ ឬរដ្ឋាភិបាលណាមួយដែលត្រូវបានធ្វើឡើងក្នុងគោលបំណងនយោបាយ សាសនា មនោគមវិជ្ជា ឬគោលដៅប្រហាក់ប្រហែលដែលរាប់បញ្ចូលទាំងចេតនាប្រើឥទ្ធិពលលើរដ្ឋាភិបាលណាមួយ និង/ឬ ធ្វើឲ្យសាធារណជន ឬក្រុមមនុស្សណាមួយមានភ័យខ្លាច។
- **អ្នកបើកបរដែលត្រូវបានផ្តល់សិទ្ធិ៖** សំដៅទៅលើ បុគ្គលណាម្នាក់ដែលបើកបរទោចក្រយានយន្តរបស់លោកអ្នកដោយមានការអនុញ្ញាតត្រឹមត្រូវ ដែលនៅក្នុងលក្ខខណ្ឌប័ណ្ណបើកបរត្រូវមានសុពលភាព និងមិនត្រូវបានដកសិទ្ធិក្នុងការបើកបរដោយច្បាប់ ឬហេតុផលណាមួយឡើង។
- **វិញ្ញាបនបត្រធានារ៉ាប់រង៖** សំដៅទៅលើវិញ្ញាបនបត្រធានារ៉ាប់រងដែលបង្កើតបានជាផ្នែកមួយ នៃបណ្ណសន្យារ៉ាប់រងដែលបញ្ជាក់ពីអ្នកត្រូវបានធានារ៉ាប់រង លេខបណ្ណសន្យារ៉ាប់រង និងព័ត៌មានពិស្តារផ្សេងទៀតដែលចេញដោយក្រុមហ៊ុន និងដែលអាចត្រូវបានធ្វើវិសោធនកម្ម បន្ថែម និង/ឬជំនួសនាពេលអនាគត។
- **ការឆបោក៖** សំដៅទៅលើ "បុគ្គលណាម្នាក់ដែលបោកបញ្ឆោត ឬបន្លំបុគ្គលម្នាក់ទៀត (អ្នកត្រូវបានគេឆបោក)ដោយឧបាយកលទុច្ចរិតដើម្បីបានទទួលនូវទ្រព្យសម្បត្តិអ្វីមួយ ឬមានចេតនាបញ្ឆោតបុគ្គលម្នាក់ទៀតនោះឲ្យចាញ់បោកព្រមប្រព្រឹត្តអំពើ ឬមិនប្រព្រឹត្តអំពើណាមួយ ដែលជននោះមិនគួរប្រព្រឹត្តតាមហើយអ្នកត្រូវបានគេឆបោកមានការខូចខាត ឬបង្កគ្រោះថ្នាក់ដល់បុគ្គលណាម្នាក់ផ្សេងទៀត ទាំងផ្លូវកាយ ផ្លូវចិត្ត កេរ្តិ៍ឈ្មោះ ឬទ្រព្យសម្បត្តិ នោះត្រូវបានចាត់ទុកថាជា "អំពើឆបោក"។
- **បទល្មើសរំលោភលើទំនុកចិត្ត៖** ត្រូវបានឲ្យនិយមន័យថា គឺជាអំពើគៃបំបាត់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ នាំឲ្យខូចប្រយោជន៍អ្នកដទៃ ប្រព្រឹត្តដោយបុគ្គលណាម្នាក់ ដែលគេបានប្រគល់ឲ្យបុគ្គលនោះ ហើយបុគ្គលនោះ បានយល់ព្រម ដោយមានភារកិច្ចប្រគល់សងវិញ បង្ហាញ ឬយកមូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិនោះ ទៅធ្វើការប្រើប្រាស់ជាកំណត់។"
- **កម្រិតមិនធ្វើសំណង៖** សំដៅទៅលើ ចំនួនទឹកប្រាក់នៃការទាមទារសំណងដែលលោកអ្នកត្រូវបង់សម្រាប់គ្រោះថ្នាក់នីមួយៗ ដូចបានបង្ហាញនៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។

24/7
ទំនាក់ទំនង២៤ម៉ោង
全天候理赔团队 | 24/7 CALL CENTER
+855 78 24 24 24 / +855 87 24 24 24
អគារលេខដីឡូតិ៍, ផ្លូវលេខ១៦៩ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
BUILDING # LAND LOT C, ST. 169, PHUM 12, SANGKAT VEAL VONG,
KHAN 7 MAKARA, PHNOM PENH, KINGDOM OF CAMBODIA.

- **បដ្ឋិលេខ៖** សំដៅទៅលើ ខសន្យាដែលក្រុមហ៊ុនអាចផ្លាស់ប្តូរការធានាដែលក្រុមហ៊ុនបានផ្តល់ជូន។ បដ្ឋិលេខណាមួយដែលអនុវត្តចំពោះកិច្ចសន្យាធានារ៉ាប់រងនេះ ត្រូវបានបង្ហាញនៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។
- **សាច់ញាតិដែលរស់នៅក្នុងផ្ទះតែមួយរបស់លោកអ្នក៖** សំដៅទៅលើ សមាជិកទាំងអស់នៃគ្រួសារជិតស្និតរបស់លោកអ្នក (ដូចជាប្តីប្រពន្ធ កូន រួមបញ្ចូលទាំង កូនចិញ្ចឹមស្របច្បាប់ ឪពុកម្តាយ បងប្អូនប្រុសស្រី) ដែលរស់នៅក្រោមដំបូលតែមួយជាមួយលោកអ្នកក្នុងករណីជា គ្រួសារជិតស្និតរបស់លោកអ្នក។
- **អ្នកត្រូវបានធានារ៉ាប់រង៖** សំដៅទៅលើ រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានរាយនាមលើវិញ្ញាបនបត្រធានារ៉ាប់រង ថាជាអ្នកត្រូវបានធានារ៉ាប់រង។
- **អំពើព្យាបាទ៖** អំពើព្យាបាទសំដៅលើទង្វើបង្កគ្រោះថ្នាក់ដោយចេតនាដែលប្រព្រឹត្តដោយបុគ្គលណាម្នាក់ ឬបុគ្គលច្រើននាក់ ដោយមានចេតនាបង្កគ្រោះថ្នាក់ និងធ្វើឱ្យខូចខាតដល់ទោចក្រយានយន្តដែលបានធានារ៉ាប់រង។
- **តម្លៃទីផ្សារ៖** សំដៅទៅលើ តម្លៃក្នុងការផ្លាស់ប្តូរទោចក្រយានយន្តរបស់លោកអ្នកជាមួយនឹងម៉ាក និងម៉ូឌែលតែមួយដូចគ្នាដែលមានសភាព និងអាយុកាលស្រដៀងគ្នាទៅនឹងទោចក្រយានយន្តរបស់លោកអ្នកពីមុន និងដែលអាចរកបានភ្លាមៗនាពេលបច្ចុប្បន្នមុនកាលបរិច្ឆេទនៃការបាត់បង់ ឬគ្រោះថ្នាក់។
- **ទោចក្រយានយន្ត៖** សំដៅទៅលើ យានជំនិះដែលបានពិពណ៌នានៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រង និងរួមបញ្ចូលគ្រឿងបរិក្ខារដែលមានស្តង់ដារពីរោងចក្រ និងគ្រឿងបរិក្ខារផ្សេងទៀត និងគ្រឿងដែលមិនស្តង់ដារផ្សេងៗដូចដែលបានរៀបរាប់នៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រង ។
- **រយៈពេលនៃការធានារ៉ាប់រង៖** សំដៅទៅលើ រយៈពេលនៃការធានារ៉ាប់រងដែលទោចក្រយានយន្តរបស់លោកអ្នកត្រូវបានធានានៅក្រោមកិច្ចសន្យាធានារ៉ាប់រងនេះ ដូចដែលបានបង្ហាញនៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។
- **កិច្ចសន្យាធានារ៉ាប់រង៖** សំដៅទៅលើ បណ្ណសន្យារ៉ាប់រងរួមជាមួយគ្នានឹងវិញ្ញាបនបត្រធានារ៉ាប់រង សេចក្តីប្រកាសការបន្តកិច្ចសន្យាធានារ៉ាប់រង បដ្ឋិលេខ និង/ឬការកែប្រែណាមួយដែលត្រូវបានអនុម័តដោយក្រុមហ៊ុន (មួយណាដែលអាចអនុវត្តបាន)។
- **យានដ្ឋានជួសជុល៖** សំដៅទៅលើ យានដ្ឋានជួសជុលយានយន្តដែលត្រូវបានយល់ព្រមដោយយើងខ្ញុំ។
- **ទឹកប្រាក់ដែលត្រូវបានធានារ៉ាប់រង៖** សំដៅទៅលើ ចំនួនអតិបរមាដែលយើងខ្ញុំនឹងបង់ជូនសម្រាប់ការទាមទារសំណងទៅលើការបាត់បង់ ឬការខូចខាតចំពោះទោចក្រយានយន្តរបស់លោកអ្នក។
- **តតិយជន៖** សំដៅទៅលើ បុគ្គលណាម្នាក់ដែលមិនត្រូវបានរាប់បញ្ចូលជាផ្នែកមួយនៃកិច្ចសន្យានេះ និងមិនត្រូវបានរាប់បញ្ចូលទាំងសាច់ញាតិដែលរស់នៅក្នុងផ្ទះតែមួយរបស់លោកអ្នក ដែលទទួលរងរបួសលើរូបរាងកាយ ពិការភាព ឬបាត់បង់ជីវិត នៅពេលដែលមានគ្រោះថ្នាក់ចរាចរណ៍។
- **យើងខ្ញុំ ឬក្រុមហ៊ុន ឬរបស់យើង៖** សំដៅទៅលើ ក្រុមហ៊ុន **អង្គរ ជេនេរ៉ល អ៊ិនសួរេន ម.ក**។

24/7
ទំនាក់ទំនង២៤ម៉ោង
全天候理赔团队 | 24/7 CALL CENTER
+855 78 24 24 24 / +855 87 24 24 24
អគារលេខដីឡូតិ៍, ផ្លូវលេខ១៦៩ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
BUILDING # LAND LOT C, ST. 169, PHUM 12, SANGKAT VEAL VONG,
KHAN 7 MAKARA, PHNOM PENH, KINGDOM OF CAMBODIA.

- **លោកអ្នក៖** សំដៅទៅលើអ្នកកាន់កិច្ចសន្យាធានារ៉ាប់រង ឬបុគ្គលដែលត្រូវបានរៀបរាប់នៅក្នុង វិញ្ញាបនបត្រធានារ៉ាប់រង ជា"អ្នកត្រូវបានធានារ៉ាប់រង"។

ផ្នែកទី ២៖ កម្មវត្ថុនៃការធានា

កម្មវត្ថុនៃការធានានៅក្រោមកិច្ចសន្យាធានារ៉ាប់រងនេះ ផ្តល់ការធានារ៉ាប់រងលើការបាត់បង់ ឬការខូចខាតទៅលើទោចក្រយានយន្តរបស់លោកអ្នក ការៈទទួលខុសត្រូវចំពោះតតិយជនលើរងរបួសលើរូបរាងកាយ ឬបាត់បង់ជីវិត និងការខូចខាតទ្រព្យសម្បត្តិរបស់តតិយជន។ កម្មវត្ថុនៃការធានានេះត្រូវអនុលោមទៅតាម ខចែង លក្ខខណ្ឌ ដែនកំណត់ និងករណីមិនធានានៃកិច្ចសន្យាធានារ៉ាប់រងនេះ។

ផ្នែកទី ៣៖ និសាលភាពធានារ៉ាប់រង

៣.១ ផ្នែក ក. ការបាត់បង់ ឬការខូចខាត

ផ្នែកមួយនេះពន្យល់លោកអ្នកអំពីការធានារ៉ាប់រងដែលយើងខ្ញុំបានផ្តល់ជូននៅក្រោម ផ្នែក ក និង អនុវត្តលុះត្រាតែលោកអ្នកមានការធានារ៉ាប់រងគ្រប់ផ្នែកតែប៉ុណ្ណោះ។

១. ក្រុមហ៊ុននឹងធ្វើការធានារ៉ាប់រងដល់លោកអ្នក ប្រសិនបើទោចក្រយានយន្តរបស់លោកអ្នកត្រូវបានទទួលរងការខូចខាត ឬ ត្រូវបានបាត់បង់នៅក្នុងកាលៈទេសៈដូចខាងក្រោម៖

ក. ដោយការប៉ះទង្គិចគ្នា ឬដួលដោយចៃដន្យ

ខ. ដោយការប៉ះទង្គិចគ្នា ឬដួលដែលបណ្តាលមកពីការខូចខាតគ្រឿងម៉ាស៊ីនគ. ដោយការប៉ះទង្គិចគ្នា ឬដួលដែលបណ្តាលមកពីការសឹករេចរឹល

ឃ. ការខូចខាតដោយសាររងផលប៉ះពាល់ ដែលបណ្តាលមកពីការធ្លាក់វត្ថុណាមួយ (ដោយពុំរួមបញ្ចូលផលប៉ះពាល់ដែលបណ្តាលមកពីករណីទឹកជំនន់ ព្យុះទីហ្វុង ខ្យល់ព្យុះ ព្យុះភ្លៀង បន្ទុះភ្នំភ្លើង រញ្ជួយដី ការបាក់ដី បំណាក់ស្រុតដី ការធ្លាក់ចុះនៃកម្រិតដី ឬផែនដី ឬគ្រោះធម្មជាតិផ្សេងទៀតដែលជាប់ពាក់ពន្ធ

ង. ដោយសារ អគ្គិភ័យ បន្ទុះ ឬរន្ទះបាញ់

ច. ដោយសារអំពើលួច ការគាស់ផ្ទះ ឬអំពើចោរកម្ម ប៉ុន្តែយើងខ្ញុំមិនធានាចំពោះការបាត់បង់ ឬការខូចខាតចំពោះគ្រឿងបន្លាប់បន្សំ ឬគ្រឿងបន្លាស់ណាមួយនៃ

ទំនាក់ទំនង២៤ម៉ោង
全天候理赔团队 | 24/7 CALL CENTER
+855 78 24 24 24 / +855 87 24 24 24
អគារលេខដីឡូតិ៍, ផ្លូវលេខ១៦៥ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
BUILDING # LAND LOT C, ST. 169, PHUM 12, SANGKAT VEAL VONG, KHAN 7 MAKARA, PHNOM PENH, KINGDOM OF CAMBODIA.

ទោចក្រយានយន្តរបស់លោកអ្នកឡើយ លុះត្រាតែទោចក្រ យានយន្តរបស់លោកអ្នក ត្រូវបានលួចក្នុងពេលជាមួយគ្នា

ឆ. ដោយអំពើព្យាបាទ

ជ. នៅពេលដែលទោចក្រយានយន្តរបស់លោកអ្នកត្រូវបានដឹកជញ្ជូនពីកន្លែងមួយ ទៅកន្លែងមួយទៀត (ដោយរួមបញ្ចូលនូវការលើកឡើង និងដាក់ចុះទោចក្រយានយន្ត) តាមរយៈផ្លូវគោក ផ្លូវដែក ឬផ្លូវទឹក។

២. ការដឹកជញ្ជូនទោចក្រយានយន្តដែលខូចខាត

យើងខ្ញុំនឹងបង់ជូនលោកអ្នកនូវទឹកប្រាក់ជាអតិបរមាចំនួន ៥០.០០ (ហាសិប) ដុល្លារអាមេរិក សម្រាប់កម្រៃសេវានៃការយកទោចក្រយានយន្ត របស់លោកអ្នកទៅកាន់យានដ្ឋានជិតបំផុត ដែលឯកភាពដោយក្រុមហ៊ុន ឬចំពោះកម្រៃសេវានៃការយកទោចក្រយានយន្តរបស់លោកអ្នក ត្រឡប់ទៅអាសយដ្ឋានរបស់លោកអ្នកដូច ដែលបានបង្ហាញនៅក្នុង ឬចំពោះថ្លៃនៃការយក ទោចក្រយានយន្តទៅទីសុវត្ថិភាព ដើម្បីរក្សាទុកក្នុងលក្ខខណ្ឌដែលទោចក្រយានយន្តរបស់លោកអ្នក ត្រូវបានទទួលរងការខូចខាតដោយហេតុការណ៍ទាំងឡាយ ដូចបានពិពណ៌នានៅក្នុងផ្នែកនេះ។

៣.២. ផ្នែក ខ. ការៈទទួលខុសត្រូវចំពោះតតិយជន

១. ក្រុមហ៊ុននឹងផ្តល់សំណងលើការៈទទួលខុសត្រូវស្របច្បាប់ក្នុងការចំណាយ (ដែលរួមបញ្ចូលរាល់សោហ៊ុយ និងការចំណាយទាំងអស់ របស់អ្នកទាមទារសំណង) សម្រាប់គ្រោះថ្នាក់ដែលបណ្តាលមកពី ឬកើតឡើងមកពីការប្រើប្រាស់ទោចក្រយានយន្តរបស់លោកអ្នក ឬមានទំនាក់ទំនងជាមួយនឹងការលើក ឬដាក់ចុះទោចក្រយានយន្តរបស់លោកអ្នក ឬអ្នកបើកបរទោចក្រយានយន្ត ដែលមានការអនុញ្ញាតរបស់លោកអ្នកសម្រាប់ចំនួនទឹកប្រាក់ដែលត្រូវទទួលខុសត្រូវលើហានិភ័យដែលបណ្តាលឲ្យ៖

ក. បាត់បង់ជីវិត ឬរងរបួសលើរូបរាងកាយ ចំពោះបុគ្គលណាម្នាក់ រហូតដល់

ទឹកប្រាក់ជាអតិបរមាចំនួន៥ ០០០.០០ (ប្រាំពាន់) ដុល្លារអាមេរិក ចំពោះជនរងគ្រោះម្នាក់ក្នុងគ្រោះថ្នាក់មួយករណី

24/7
ទំនាក់ទំនង២៤ម៉ោង
全天候理赔团队 | 24/7 CALL CENTER
+855 78 24 24 24 / +855 87 24 24 24

អគារលេខដីឡូតិ៍, ផ្លូវលេខ១៦៥ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
BUILDING # LAND LOT C, ST. 169, PHUM 12, SANGKAT VEAL VONG,
KHAN 7 MAKARA, PHNOM PENH, KINGDOM OF CAMBODIA.

ខ. ការខូចខាតលើទ្រព្យសម្បត្តិដែលបណ្តាលមកពីគ្រោះថ្នាក់ កើតឡើងដោយការប្រើប្រាស់ទោចក្រយានយន្តរបស់លោកអ្នក រហូតដល់ទឹកប្រាក់ជាអតិបរមាចំនួន ៥ ០០០.០០ (ប្រាំពាន់) ដុល្លារអាមេរិក ក្នុងគ្រោះថ្នាក់មួយករណី។

អ្នកបើកបរដែលត្រូវបានផ្តល់សិទ្ធិរបស់លោកអ្នកត្រូវអនុវត្តតាមខចែង និងលក្ខខណ្ឌនៃកិច្ចសន្យាធានារ៉ាប់រងនេះដូចដែលលោកអ្នកបានអនុវត្ត។

២. ដែនកំណត់នៃការៈទទួលខុសត្រូវ

ការៈទទួលខុសត្រូវសរុបរបស់យើងខ្ញុំនៅក្រោមផ្នែក ខ (១.ក) ខ(១.ខ) និងខ(៤) ដែលទាក់ទងនឹងការទាមទារសំណងណាមួយ ឬការទាមទារសំណងជាបន្តបន្ទាប់ដែលកើតឡើង នៃព្រឹត្តិការណ៍មួយ គឺត្រូវបានកំណត់ត្រឹមតែ ៥០០០០.០០ (ហាសិបពាន់)ដុល្លារអាមេរិក ប៉ុណ្ណោះ។

៣. អ្នកតំណាងស្របច្បាប់

បន្ទាប់ពីមានការបាត់បង់ជីវិតលើបុគ្គលណាម្នាក់ ដែលត្រូវបានធានានៅក្រោមកិច្ចសន្យាធានារ៉ាប់រងនេះ យើងខ្ញុំនឹងផ្តល់សំណងជូនដល់អ្នកតំណាងស្របច្បាប់របស់បុគ្គលនោះ ចំពោះការៈទទួលខុសត្រូវដែលត្រូវបានធានានៅក្រោមផ្នែកមួយនេះ នៅក្នុងលក្ខខណ្ឌដែលអ្នកតំណាងស្របច្បាប់នោះគោរពតាម ខចែង និងលក្ខខណ្ឌ នៃកិច្ចសន្យាធានារ៉ាប់រង។

៤. សោហ៊ុយផ្នែកច្បាប់

ក្រុមហ៊ុននឹងបង់ចំពោះសោហ៊ុយផ្នែកច្បាប់ដែលកើតឡើង រហូតដល់ទឹកប្រាក់ជា អតិបរមាចំនួន ១,៥០០.០០ (មួយពាន់ប្រាំរយ) ដុល្លារអាមេរិក សម្រាប់ការពារក្តីពីការចោទប្រកាន់ណាមួយដោយរួមបញ្ចូល ការចោទប្រកាន់ពីបទធ្វើឲ្យបាត់បង់ជីវិត ដោយសារការបើកបរទោចក្រយានយន្ត (ក្រៅពីបទមនុស្សឃាតដោយចេតនា) ប្រសិនបើមានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីខាងក្រុមហ៊ុន។

៣.៣. ជម្រើសអត្ថប្រយោជន៍បន្ថែម

អត្ថប្រយោជន៍បន្ថែមខាងក្រោមនេះនឹងមិនត្រូវបានអនុវត្តនោះទេ លុះត្រាតែមានបញ្ជាក់នៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។

24/7
ទំនាក់ទំនង២៤ម៉ោង
全天候理赔团队 | 24/7 CALL CENTER
+855 78 24 24 24 / +855 87 24 24 24
អគារលេខដីឡូតិ៍, ផ្លូវលេខ១៦៥ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
BUILDING # LAND LOT C, ST. 169, PHUM 12, SANGKAT VEAL VONG,
KHAN 7 MAKARA, PHNOM PENH, KINGDOM OF CAMBODIA.

១. កូដកម្ម កុបកម្ម និងភាពចលាចលស៊ីវិល

ដោយយោងលើការបង់បុព្វលាភធានារ៉ាប់រងបន្ថែម ក្រុមហ៊ុនធានារ៉ាប់រង អះអាងនិងព្រមព្រៀងថា ការធានារ៉ាប់រងនៅក្រោមបណ្ណសន្យារ៉ាប់រងនេះ នឹងបន្ថែមការធានារ៉ាប់រងលើការខូចខាត ឬការខាតបង់ដែលបណ្តាលមកពីការធ្វើកុប្បកម្ម, កូដកម្ម និងភាពចលាចលស៊ីវិល។

ការធ្វើកុប្បកម្ម, កូដកម្ម និង ភាពចលាចលស៊ីវិល នឹងត្រូវទទួលបានការធានារ៉ាប់រង ក្រោមរូបភាពដូចខាងក្រោម៖

ក. ទង្វើរបស់បុគ្គលដែលចូលរួមជាមួយអ្នកដទៃ ក្នុងការធ្វើមានចលាចលដល់សន្តិភាពសាធារណៈ (ទោះជាទាក់ទងនឹងការធ្វើកូដកម្ម ឬការបង្ខាំងមិនឱ្យចូលធ្វើការ ក៏ដោយ)។

ខ. សកម្មភាពរបស់អាជ្ញាធរស្របច្បាប់ការបង្ក្រាប ឬក្នុងបំណងបង្ក្រាបចលាចល ឬកាត់បន្ថយជាអតិបរមានូវផលវិបាកនៃចលាចលនេះ។

គ. ទង្វើដោយចេតនារបស់កូដករ ឬអ្នកធ្វើការដែលត្រូវបានហាមឃាត់មិនចូលធ្វើការដែលបានជំរុញបន្ថែមមានកូដកម្ម ឬការប្រឆាំងនឹងការមិនចូលធ្វើការ។

ឃ. សកម្មភាពរបស់អាជ្ញាធរស្របច្បាប់ការការពារ ឬក្នុងគោលបំណងការពារកើតមាននូវទង្វើរបៀបនេះ ឬកាត់បន្ថយជាអតិបរមា នូវផលវិបាកនៃ សកម្មភាពនេះ។

រាល់ខចែង និងលក្ខខណ្ឌទាំងអស់ត្រូវផ្អែកលើកិច្ចសន្យាធានារ៉ាប់រងនេះ។

២. ទឹកជំនន់ និងគ្រោះធម្មជាតិផ្សេងៗ

ដោយលោកអ្នកបានបង់បុព្វលាភធានារ៉ាប់រងបន្ថែមដល់យើងខ្ញុំ ហានិភ័យខាងក្រោមនេះត្រូវបានចាត់ទុកថាត្រូវបានធានានៅក្រោមផ្នែក ក នៃកិច្ចសន្យាធានារ៉ាប់រងនេះ - ហានិភ័យទាំងនោះរួមមាន៖ ទឹកជំនន់ ព្យុះទីហ្វុង ខ្យល់ព្យុះ ព្យុះភ្លៀង បន្ទុះភ្នំភ្លើង រញ្ជួយដី ការបាក់ដី បំណាក់ស្រុតដី ការធ្លាក់ចុះនៃកម្រិតដី ឬផែនដី ឬគ្រោះធម្មជាតិផ្សេងទៀតដែលត្រូវបានរួមបញ្ចូល។

រាល់ខចែង និងលក្ខខណ្ឌទាំងអស់ត្រូវផ្អែកលើកិច្ចសន្យាធានារ៉ាប់រងនេះ។

៣. គ្រោះថ្នាក់ចំពោះអ្នកបើកបរដែលត្រូវបានផ្តល់សិទ្ធិ និងអ្នករួមដំណើរ

ទំនាក់ទំនង២៤ម៉ោង
全天候理赔团队 | 24/7 CALL CENTER
+855 78 24 24 24 / +855 87 24 24 24
អគារលេខដីឡូតិ៍, ផ្លូវលេខ១៦៩ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
BUILDING # LAND LOT C, ST. 169, PHUM 12, SANGKAT VEAL VONG,
KHAN 7 MAKARA, PHNOM PENH, KINGDOM OF CAMBODIA.

ដោយលោកអ្នកបានបង់បុព្វលាភធានារ៉ាប់រងបន្ថែមដល់យើងខ្ញុំ យើងខ្ញុំទទួលយល់ព្រមធ្វើការផ្តល់សំណងតាមមាត្រដ្ឋានដែលបានផ្តល់សម្រាប់រងរបួសលើរូបរាងកាយ ដែលទទួលរងគ្រោះថ្នាក់ដោយលោកអ្នក ឬអ្នកបើកបរដែលត្រូវបានផ្តល់សិទ្ធិរបស់លោកអ្នក និងអ្នករួមដំណើរ ដូចខាងក្រោម៖

ក. ដោយមានការទំនាក់ទំនងផ្ទាល់ជាមួយយានយន្ត និង

ខ. ខណៈដែលកំពុងចូល ចេញ ឬបើកបរនៅក្នុងយានយន្ត និងត្រូវបានបង្កដោយមធ្យោបាយដែលបណ្តាលឲ្យមានគ្រោះថ្នាក់ដែលអាចមើលឃើញពីខាងក្រៅ ដែលមិនពាក់ពន្ធ័នឹងមូលហេតុដទៃទៀតណាមួយ (រួមបញ្ចូលទាំងការព្យាបាលដោយវេជ្ជសាស្ត្រ ឬដោយការវះកាត់ បន្ទាប់ពីការរងរបួសនេះ) ក្នុងរយៈពេលបីខែប្រតិទិននៃការកើតឡើងការរងរបួសនេះបណ្តាលឲ្យមាត្រដ្ឋាននៃការធ្វើសំណង៖

- ការបាត់បង់ជីវិត.....៥000.00 (ប្រាំពាន់) ដុល្លារអាមេរិក
- ការបាត់បង់ទាំងស្រុងនៃចក្ខុវិញ្ញាណទាំងពីរ និងមិនអាចព្យាបាលឲ្យដូចដើមវិញបាន.....៥000.00 (ប្រាំពាន់) ដុល្លារអាមេរិក
- ការបាត់បង់ទាំងស្រុងដោយសារការដាច់អវៈយវៈនៅត្រឹម ឬលើកដៃ ឬកជើង ឬប្រអប់ដៃទាំងពីរ ឬប្រអប់ជើងទាំងពីរ ឬប្រអប់ដៃម្ខាង ជាមួយប្រអប់ជើងម្ខាង ៥000.00 (ប្រាំពាន់) ដុល្លារអាមេរិក
- ការបាត់បង់ទាំងស្រុងដោយសារការដាច់អវៈយវៈត្រឹម ឬលើកដៃម្ខាង ឬកជើងម្ខាង រួមជាមួយនឹងការបាត់បង់ទាំងស្រុងនៃចក្ខុវិញ្ញាណម្ខាង និងដែលមិនអាចព្យាបាលឲ្យដូចដើមវិញបាន .....៥ 000.00 (ប្រាំពាន់) ដុល្លារអាមេរិក
- ការបាត់បង់ទាំងស្រុងនៃចក្ខុវិញ្ញាណម្ខាង និងមិនអាចព្យាបាលឲ្យដូចដើមវិញបាន.....៥ 000.00 (ប្រាំពាន់) ដុល្លារអាមេរិក
- ការចំណាយផ្នែកវេជ្ជសាស្ត្រហួតដល់..... ៥00.00 (ប្រាំរយ) ដុល្លារអាមេរិក។

ការទូទាត់សំណងនឹងត្រូវបានធ្វើឡើងក្រោមកថាភាគទី (១) ដល់ (៦) តែប៉ុណ្ណោះ ចំពោះការកើតឡើងណាមួយ និង ការៈទទួលខុសត្រូវសរុបរបស់ក្រុមហ៊ុននឹងមិនត្រូវលើសពី ៥000.00 (ប្រាំពាន់) ដុល្លារអាមេរិកនោះទេ ក្នុងរយៈពេលនៃការធានារ៉ាប់រងណាមួយដែរបណា៖

ក. អ្នកបើកបរមានអាយុមិនតិចជាង ១៨ឆ្នាំ ឬមិនលើស ៦៥ឆ្នាំនៅពេលមានរបួស

ទំនាក់ទំនង២៤ម៉ោង
全天候理赔团队 | 24/7 CALL CENTER
+855 78 24 24 24 / +855 87 24 24 24
អគារលេខដីឡូតិ៍, ផ្លូវលេខ១៦៥ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
BUILDING # LAND LOT C, ST. 169, PHUM 12, SANGKAT VEAL VONG,
KHAN 7 MAKARA, PHNOM PENH, KINGDOM OF CAMBODIA.

គ. ពុំមានការទូទាត់សំណងណាមួយនឹងត្រូវបានទូទាត់ឡើយចំពោះការបាត់បង់ជីវិត ឬ រងរបួសទាំងស្រុងដោយផ្ទាល់ ឬជាផ្នែកដែលកើតឡើងពី ឬដែលអាចមើលឃើញថា បណ្តាលមកពី៖

- ការធ្វើឲ្យរបួសខ្លួនឯងដោយចេតនា ការធ្វើអត្តឃាតខ្លួនឯង ឬការប៉ុនប៉ងធ្វើ អត្តឃាតដោយខ្លួនឯង (ថាតើជាបទឧក្រិដ្ឋ ឬមិនមែន) ពិការភាពផ្នែករូប រាង ឬអសមត្ថភាពផ្នែករូបរាងកាយ
- គ្រោះថ្នាក់ដែលកើតឡើងខណៈដែលបុគ្គលម្នាក់នោះកំពុងស្ថិតក្រោមឥទ្ធិ ពលនៃគ្រឿងស្រវឹង ឬគ្រឿងញៀន។

រាល់ខចែង និងលក្ខខណ្ឌទាំងអស់ត្រូវយោងលើកិច្ចសន្យាធានារ៉ាប់រងនេះ។

៤. ការដាក់បញ្ចូលនូវការៈទទួលខុសត្រូវដោយស្របច្បាប់ចំពោះអ្នករួមដំណើរ

ការធានារ៉ាប់រងដែលបានផ្តល់ជូននៅក្រោមផ្នែក ក ១ (ក) នៃកិច្ចសន្យាធានារ៉ាប់រងនេះនឹង ត្រូវអនុវត្តចំពោះ ការបាត់បង់ជីវិត ឬរងរបួសលើរូបរាងកាយចំពោះបុគ្គលណាម្នាក់ដែលកំពុង ត្រូវបានដឹកនៅក្នុង ឬនៅពេលកំពុងចូល ឬកំពុងជិះ ឬកំពុងចេញពីយានយន្តរបស់លោកអ្នក។ ដែនកំណត់នៃការៈទទួលខុសត្រូវចំពោះការបាត់បង់ជីវិត និង/ឬ រងរបួសលើរូបរាងកាយក្នុង មួយលើក គឺរហូតដល់ទឹកប្រាក់ជាអតិបរមាចំនួន ៥000.00 (ប្រាំពាន់) ដុល្លារអាមេរិក និង ៥0 000.00 (ហាសិបពាន់) ដុល្លារអាមេរិកជាចំនួនសរុបទាំងអស់សម្រាប់ការទាមទារ សំណងណាមួយក្នុងរយៈពេលនៃការធានារ៉ាប់រង។

រាល់ខចែង និងលក្ខខណ្ឌទាំងអស់ត្រូវផ្អែកលើកិច្ចសន្យាធានារ៉ាប់រងនេះ។

ផ្នែកទី ៤៖ អត្ថប្រយោជន៍នៃការធានា

បណ្ណសន្យាធានារ៉ាប់រងនេះជួយការពារលោកអ្នកពីការខាតបង់ផ្នែកហិរញ្ញវត្ថុ ក្នុងករណីមានគ្រោះថ្នាក់ អំពើ ចោរកម្ម ឬការខូចខាត។ ការធានារ៉ាប់រងនេះ ការពារលើការចំណាយលើការព្យាបាលវេជ្ជសាស្ត្រ ថ្លៃជួសជុល និង ការៈទទួលខុសត្រូវលើភាគីទីបី ដើម្បីធានាថាលោកអ្នកបើកបរដោយសន្តិភាពផ្លូវចិត្ត។

អត្ថប្រយោជន៍ស្នូលដែលទទួលបានពីបណ្ណសន្យាធានារ៉ាប់រងនេះរួមមាន៖

ក. ការការពារហិរញ្ញវត្ថុលើការខូចខាតទោចក្រយានយន្ត លើការចំណាយលើការជួសជុល ឬផ្លាស់ប្តូរ ទោចក្រយានយន្តរបស់លោអ្នក ប្រសិនបើមានការខូចខាតដោយសារគ្រោះថ្នាក់ចៃដន្យ ឬអំពើរចោរកម្ម។

24/7
ទំនាក់ទំនង២៤ម៉ោង
全天候理赔团队 | 24/7 CALL CENTER
+855 78 24 24 24 / +855 87 24 24 24
អគារលេខដីឡូតិ៍, ផ្លូវលេខ១៦៩ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
BUILDING # LAND LOT C, ST. 169, PHUM 12, SANGKAT VEAL VONG,
KHAN 7 MAKARA, PHNOM PENH, KINGDOM OF CAMBODIA.

ខ. ការធានារ៉ាប់រងលើភារៈទទួលខុសត្រូវលើភាគីទីបី៖ ការធ្វើសំណងសម្រាប់ករណីរបួសរូបរាងកាយ ការបាត់បង់អាយុកជីវិត ឬការខូចខាតទ្រព្យសម្បត្តិដែលអ្នកបានបង្កដោយអចេតនាដល់ភាគីទីបី។

គ. ការធានារ៉ាប់រងគ្រោះថ្នាក់ផ្ទាល់ខ្លួន និងការចំណាយលើការព្យាបាលផ្នែកវេជ្ជសាស្ត្រ៖ ការធ្វើសំណងលើការព្យាបាល ឬផ្តល់សំណងសម្រាប់ករណីរងរបួស ឬពិការភាពដែលកើតឡើងលើអ្នករួមបើកបរ ឬអ្នករួមដំណើរក្នុងអំឡុងពេលមានគ្រោះថ្នាក់។

ឃ. ការធានារ៉ាប់រងលើមហន្តរាយធម្មជាតិ៖ ការពារទោចក្រយានយន្តរបស់លោកអ្នកពីការបាត់បង់ដែលមិនបានរំពឹងទុក ដែលបណ្តាលមកពីព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ ដូចជាទឹកជំនន់ ឬរញ្ជួយដី។

ង. ការបញ្ចុះតម្លៃសម្រាប់ករណីគ្មានការទាមទារសំណង៖ ផ្តល់ជូនការបញ្ចុះតម្លៃលើបុព្វលាភធានារ៉ាប់រងនៅពេលបន្តកិច្ចសន្យា ប្រសិនបើលោកអ្នករក្សាបានកំណត់ត្រាបើកបរដោយសុវត្ថិភាព និងមិនមានការទាមទារសំណងក្នុងអំឡុងពេលសុពលភាព។

ផ្នែកទី ៥៖ ការបង់បុព្វលាភធានារ៉ាប់រង

ការបង់បុព្វលាភគឺត្រូវបង់ជាប្រចាំឆ្នាំ និង គណនាបុព្វលាភទៅតាមសមាមាត្រប្រសិនបើមានការបន្ថែម ឬលុបចោលណាមួយនៅក្នុងរយៈពេលធានារ៉ាប់រង។

នេះគឺជាលក្ខខណ្ឌពិសេសជាមូលដ្ឋាន និងតែមួយគត់នៃកិច្ចសន្យាធានារ៉ាប់រងនេះដែលតម្រូវថាបុព្វលាភធានារ៉ាប់រងដែលដល់ពេលត្រូវបង់គឺត្រូវតែបង់ និងទទួលបានដោយក្រុមហ៊ុនក្នុងរយៈពេល៣០(សាមសិប)ថ្ងៃគិតចាប់ពីកាលបរិច្ឆេទចាប់ផ្តើមកិច្ចសន្យានេះ/បដ្ឋិលេខ/លិខិតបញ្ជាក់អំពីការបន្តកិច្ចសន្យា។ ប្រសិនបើលក្ខខណ្ឌនេះមិនត្រូវបានអនុវត្តតាមនោះទេកិច្ចសន្យានេះនឹងត្រូវបានចាត់ទុកជាមោយៈដោយស្វ័យប្រវត្តិ ហើយក្រុមហ៊ុនមានសិទ្ធិទទួលបានបុព្វលាភធានារ៉ាប់រងតាមសមាមាត្រនៃរយៈពេលដែលខ្លួនស្ថិតនៅក្នុងហានិភ័យ។

រាល់លក្ខខណ្ឌដែលបានចែងទាំងអស់ត្រូវយោងលើកិច្ចសន្យាធានារ៉ាប់រងនេះ។ អ្នកត្រូវបានធានារ៉ាប់រងអាចធ្វើការបង់បុព្វលាភធានារ៉ាប់រងមកកាន់ក្រុមហ៊ុនតាមរយៈ ៖ ការបង់ជាសាច់ប្រាក់ ការបង់ជាមូលប្បទានបត្រ កម្មវិធីទូទាត់ផ្សេងៗរបស់ក្រុមហ៊ុន ឬក៏ផ្ទេរតាមរយៈគណនីធនាគារផ្ទាល់របស់ក្រុមហ៊ុន **អង្គរ ជេនេរ៉ល អ៊ិនសួរេន ម.ក** ។

ទំនាក់ទំនង២៤ម៉ោង
全天候理赔团队 | 24/7 CALL CENTER
+855 78 24 24 24 / +855 87 24 24 24
អគារលេខដីឡូតិ៍, ផ្លូវលេខ១៦៩ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
BUILDING # LAND LOT C, ST. 169, PHUM 12, SANGKAT VEAL VONG, KHAN 7 MAKARA, PHNOM PENH, KINGDOM OF CAMBODIA.

ផ្នែកទី ៦: ករណីមិនធានា

ក្រុមហ៊ុននឹងមិនធ្វើសំណងចំពោះការៈទទួលខុសត្រូវក្រោមកាលៈទេសៈដូចខាងក្រោម៖

៦.១. ករណីមិនធានាពិសេសអនុវត្តចំពោះផ្នែក ក

យើងខ្ញុំនឹងមិនធ្វើសំណងចំពោះ៖

ក. ផលវិបាកការខាតបង់ផ្នែកហិរញ្ញវត្ថុ
ដោយសារការមិនអាចប្រើប្រាស់នៃទោចក្រយានយន្តរបស់លោកអ្នក បន្ទាប់ពីទោចក្រយានយន្តទទួលរងការខូចខាត។

ខ. ការរំលស់ថ្លៃ
ការរំលស់ថ្លៃ ការសឹករេចរឹល ច្រែះស៊ី និងការពុក ការខូចផ្នែកគ្រឿងម៉ាស៊ីន ឬផ្នែកអគ្គិសនី ឬផ្នែកអេឡិចត្រូនិក ដំណើរការមិនប្រក្រតីនៃឧបករណ៍ ឬប្រព័ន្ធកុំព្យូទ័ររបស់ទោចក្រយានយន្តការខូចខាត ឬការបាក់បែកនៃ ឬការបែកបាក់នៃទោចក្រយានយន្តរបស់លោក។

គ. ការខូចខាតចំពោះសំបកកង់
ការខូចខាតចំពោះសំបកកង់ទោចក្រយានយន្តរបស់លោកអ្នកដូចជាបែក ឬ ធ្លាយលើកលែងតែទោចក្រយានយន្តរបស់លោកអ្នកត្រូវបានខូចខាតនៅក្នុងពេលជាមួយគ្នាដោយសារគ្រោះថ្នាក់ជាយថាហេតុ។

ឃ. បទល្មើសរំលោភលើទំនុកចិត្ត
ការបាត់បង់ ឬការខូចខាតណាមួយដែលបណ្តាលមកពី ឬសន្មត់ថាមកពីអំពើឆបោក/បទល្មើសការរំលោភលើទំនុកចិត្ត ដោយបុគ្គលណាម្នាក់ស្របតាមនិយមន័យ នៃបទល្មើឆបោក/បទល្មើសរំលោភលើទំនុកចិត្ត។

ង. ការបាត់បង់ ចំពោះគ្រឿងបន្ទាប់បន្សំ ឬគ្រឿងបន្លាស់
ការបាត់បង់ ឬការខូចខាតចំពោះគ្រឿងបរិក្ខារ ឬគ្រឿងបន្លាស់ណាមួយនៃទោចក្រយានយន្តរបស់លោកអ្នកដោយសារអំពើលួច ការគាស់ផ្ទះ ឬអំពើចោរកម្ម លុះត្រាតែទោចក្រយានយន្តរបស់លោកអ្នកត្រូវបានលួចក្នុងពេលតែមួយ។

ច. កម្រិតមិនធ្វើសំណង

ទំនាក់ទំនង២៤ម៉ោង
全天候理赔团队 | 24/7 CALL CENTER
+855 78 24 24 24 / +855 87 24 24 24
អគារលេខដីឡូតិ៍, ផ្លូវលេខ១៦៩ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
BUILDING # LAND LOT C, ST. 169, PHUM 12, SANGKAT VEAL VONG,
KHAN 7 MAKARA, PHNOM PENH, KINGDOM OF CAMBODIA.

កម្រិតមិនធ្វើសំណងដូចបានចែងនៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។ លោកអ្នកត្រូវតែទទួលខុសត្រូវចំពោះចំនួននៃកម្រិតមិនធ្វើសំណង រៀងរាល់ការទាមទារសំណងនៅក្រោមកិច្ចសន្យាធានារ៉ាប់រងនេះ។

ឆ. ការចំណាំកាលបរិច្ឆេទ
ដំណើរការមិនប្រក្រតី ឬអសមត្ថភាពនៃឧបករណ៍ ឬកម្មវិធីកុំព្យូទ័រ ក្នុងការអានកាលបរិច្ឆេទដើម្បីប្រតិបត្តិការណ៍ ឬដំណើរការឲ្យបានត្រឹមត្រូវដូចទៅនឹងកាលបរិច្ឆេទនៃប្រតិទិន។

៦.២. ករណីមិនធានាពិសេសអនុវត្តចំពោះផ្នែក

ក្រុមហ៊ុននឹងមិនផ្តល់សំណងដែលពាក់ព័ន្ធនឹង៖

ក. ការបាត់បង់ជីវិត ឬរងរបួសលើរូបរាងកាយចំពោះបុគ្គលណាម្នាក់ ឬការខូចខាតលើទ្រព្យសម្បត្តិដែលបណ្តាលមកពី ឬកើតឡើងក្រៅដែនកំណត់នៃផ្លូវដឹកជញ្ជូន ឬផ្លូវគ្លា ដែលមានទំនាក់ទំនងជាមួយនឹងការលើកដាក់ និងយកចេញពីទោចក្រយានយន្តរបស់លោកអ្នក។

ខ. ការបាត់បង់ជីវិត ឬរងរបួសលើរូបរាងកាយចំពោះបុគ្គលណាម្នាក់ ដែលកើតឡើង និងពាក់ព័ន្ធនឹងបុគ្គលដែលបម្រើការងារឲ្យលោកអ្នក ឬអ្នកបើកបរដែលត្រូវបានផ្តល់សិទ្ធិរបស់លោកអ្នក។

គ. ការខូចខាតលើទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិ ឬក្រោមការកាន់កាប់ ឬក្រោមការគ្រប់គ្រង ឬក្រោមការថែរក្សារបស់លោកអ្នក និង/ឬអ្នកបើកបរដែលត្រូវបានផ្តល់សិទ្ធិរបស់លោកអ្នក និង/ឬសមាជិកណាម្នាក់នៃគ្រួសាររបស់លោកអ្នក និង/ឬសមាជិកណាម្នាក់នៃគ្រួសាររបស់អ្នកបើកបរដែលត្រូវបានផ្តល់សិទ្ធិរបស់លោកអ្នក។

ឃ. ការៈទទួលខុសត្រូវចំពោះបុគ្គលណាម្នាក់ដែលត្រូវបានកំពុងឡើងជិះ ឬចុះពីទោចក្រយានយន្តរបស់លោកអ្នក (លុះត្រាតែបុគ្គលនោះត្រូវបានតម្រូវឲ្យដឹកនៅលើទោចក្រយានយន្តរបស់លោកអ្នកដោយហេតុណាមួយជាក់លាក់ ឬដោយអនុលោមតាមកិច្ចសន្យាការងាររបស់បុគ្គលនោះ ជាមួយលោកអ្នក និង/ឬ អ្នកបើកបរដែលត្រូវបានផ្តល់សិទ្ធិរបស់លោកអ្នក និង/ឬ និយោជករបស់បុគ្គលម្នាក់នោះ។

ង. ការទាមទារសំណងណាមួយដែលត្រូវបានធ្វើឡើងដើម្បីប្រឆាំងនឹងបុគ្គលណាម្នាក់ រាល់សោហ៊ុយ និងការចំណាយទាំងអស់ទាក់ទងនឹងបណ្តឹងនៃវិវាទ ដែលមិនត្រូវបានធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ទំនាក់ទំនង២៤ម៉ោង
全天候理赔团队 | 24/7 CALL CENTER
+855 78 24 24 24 / +855 87 24 24 24
អគារលេខដីឡូតិ៍, ផ្លូវលេខ១៦៩ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
BUILDING # LAND LOT C, ST. 169, PHUM 12, SANGKAT VEAL VONG,
KHAN 7 MAKARA, PHNOM PENH, KINGDOM OF CAMBODIA.

ច. រាល់អ្នកធ្វើដំណើរលើទោចក្រយានយន្ត ដែលត្រូវបានធានារ៉ាប់រង មិនថាជិះពីខាងក្រោយ ឬអត់ នឹងមិនត្រូវបានធានានៅក្រោមធានារ៉ាប់រងនេះឡើយ។

៦.៣. ករណីមិនធានាទូទៅអនុវត្តចំពោះផ្នែកទាំងពីរ (ក និងខ)

ក. អ្នកបើកបរដែលគ្មានបណ្ណបើកបរ

ប្រសិនបើលោកអ្នក ឬបុគ្គលណាម្នាក់ដែលអនុញ្ញាតដោយលោកអ្នកមិនមានបណ្ណបើកបរទោចក្រយានយន្ត លើកលែងតែមានការអនុញ្ញាតដោយច្បាប់ និងបទប្បញ្ញត្តិធរមាននៃព្រះរាជាណាចក្រកម្ពុជា។

ខ. គ្រឿងស្រវឹង ថ្នាំញៀន និងសារធាតុគ្រឿងញៀនផ្សេងៗ

ប្រសិនបើលោកអ្នក ឬអ្នកបើកបរដែលត្រូវបានផ្តល់សិទ្ធិរបស់លោកអ្នក បើកបរទោចក្រយានយន្តរបស់លោកអ្នកស្ថិតក្នុងស្ថានភាពស្រវឹង ឬគ្រឿងញៀន។

គ. ការប្រើប្រាស់ក្នុងគោលបំណងល្មើសច្បាប់

- ការបាត់បង់ ការខូចខាត ឬការៈទទួលខុសត្រូវណាមួយដែលបណ្តាលមកពីទោចក្រយានយន្តរបស់លោកអ្នកដែលត្រូវបានប្រើប្រាស់ក្នុងគោលបំណងមិនស្របច្បាប់ ឬដែលត្រូវបានប្រើប្រាស់ពុំស្របច្បាប់តាមកម្រិតដោយលោកអ្នក ឬបុគ្គលដទៃទៀតដោយមានការយោលព្រមពីលោកអ្នក។
- ការបាត់បង់ ការខូចខាត ឬការៈទទួលខុសត្រូវដែលបណ្តាលឲ្យ ទទួលរង ឬកើតឡើងក្នុងអំឡុងពេលទោចក្រយានយន្តរបស់លោកអ្នកដែលធានាដោយកិច្ចសន្យាធានារ៉ាប់រងនេះ ត្រូវបានកំពុងបើកបរដោយបុគ្គលណាម្នាក់ក្រៅពីអ្នកបើកបរដែលត្រូវបានផ្តល់សិទ្ធិ ឬបុគ្គលដែលមានការបញ្ជា ឬការអនុញ្ញាតពីលោកអ្នក។

ឃ. ហានិភ័យនៃសង្គ្រាម
ប្រសិនបើការបាត់បង់ ការខូចខាត ឬការៈទទួលខុសត្រូវណាមួយដែលបណ្តាលមកពីការឈ្លានពាន សង្គ្រាម (ទោះជាសង្គ្រាមនោះត្រូវបានប្រកាស់ ឬមិនត្រូវបានប្រកាសក៏ដោយ) ប្រតិបត្តិការសង្គ្រាម សត្រូវបរទេស ចម្បាំង សង្គ្រាមស៊ីវិល អំពើភេរវកម្ម កូដកម្ម កុបកម្ម ចលាចលស៊ីវិល ការបះបោរ ចលនាឧទ្ទាម បដិវត្តន៍ ការប្រើកម្លាំងទ័ព ឬការដណ្តើមអំណាច ឬផលវិបាកផ្សេងទៀតដោយផ្ទាល់ ឬដោយប្រយោលនៃហេតុការណ៍ទាំងនោះ។

ង. ទឹកជំនន់ និងគ្រោះធម្មជាតិផ្សេងៗ

ទំនាក់ទំនង២៤ម៉ោង
全天候理赔团队 | 24/7 CALL CENTER
+855 78 24 24 24 / +855 87 24 24 24
អគារលេខដីឡូតិ៍, ផ្លូវលេខ១៦៥ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
BUILDING # LAND LOT C, ST. 169, PHUM 12, SANGKAT VEAL VONG, KHAN 7 MAKARA, PHNOM PENH, KINGDOM OF CAMBODIA.

ប្រសិនបើការបាត់បង់ ការខូចខាត ឬការៈទទួលដោយផ្ទាល់ ឬដោយប្រយោលដែលបណ្តាលមកពី ឬការចូលរួម ឬកើតឡើងមកពី ទឹកជំនន់ ព្យុះទីហ្វុង ខ្យល់ព្យុះ ព្យុះភ្លៀង បន្ទុះភ្នំភ្លើង រញ្ជួយដី ការបាក់ដី បំណាក់ស្រុតដី ការធ្លាក់ចុះនៃកម្រិតដី ឬផែនដី ឬគ្រោះធម្មជាតិផ្សេងទៀតដែលត្រូវបានរួមបញ្ចូល។

ច. ការប្រើប្រាស់សម្រាប់ការប្រណាំង ឬធ្វើការសាកល្បង

ប្រសិនបើទោចក្រយានយន្តរបស់លោកអ្នកត្រូវបានប្រើប្រាស់សម្រាប់ ឬធ្វើសាកល្បងនៅក្នុងការរៀបចំសម្រាប់កីឡា ឬការប្រកួតប្រជែងទោចក្រយានយាន្តណាមួយ។ សកម្មភាពទាំងនេះរួមមានជាអាទិ៍ ការសាកល្បងភាពដែលអាចទុកចិត្តបាន ការសាកល្បងបើកឡើងភ្នំ និងការប្រណាំងនានា។

ឆ. ការខកខានក្នុងការអនុវត្តការប្រុងប្រយ័ត្ន

ប្រសិនបើនៅក្នុងព្រឹត្តិការណ៍នៃការគ្រោះថ្នាក់ ឬការខូចខាតណាមួយ ទោចក្រយានយន្តរបស់លោកអ្នកត្រូវបានទុកចោល ដោយគ្មានវិធានការការពារឲ្យបានត្រឹមត្រូវ ដើម្បីទប់ស្កាត់ការបាត់បង់ ឬការខូចខាតផ្សេងទៀត និងប្រសិនបើទោចក្រយានយន្តរបស់លោកអ្នកត្រូវបានបើកបរក្នុងស្ថានភាពដែលពុំអាចបើកបរបាន មុនពេលមានការជួសជុលចាំបាច់នានាត្រូវបានធ្វើឡើង នោះការខូចខាតបន្ថែម ឬការខូចខាតផ្សេងទៀតចំពោះទោចក្រយានយន្តរបស់លោកអ្នកនឹងមិនត្រូវបានធានាដោយកិច្ចសន្យាធានារ៉ាប់រងនេះឡើយ។ ប៉ុន្តែយើងក្រុមហ៊ុននឹងធានាការបាត់បង់ ឬការខូចខាត នៅក្នុងលក្ខខណ្ឌដែលលោកអ្នកមានហេតុផលសមស្របណាមួយអំពីគោលបំណងនៃការទុកចោល ឬបន្តក្នុងការជិះទោចក្រយានយន្តរបស់លោកអ្នក។

ជ. ការប្រើប្រាស់នៅក្រៅព្រះរាជាណាចក្រកម្ពុជា

ចំពោះការបាត់បង់ ការខូចខាត ឬការៈទទួលខុសត្រូវដោយថាហេតុណាមួយ ដែលបណ្តាលមកពីទទួលរង ឬកើតឡើងនៅក្រៅព្រះរាជាណាចក្រកម្ពុជា។

ឈ. ការៈទទួលខុសត្រូវលើកិច្ចសន្យា

យើងខ្ញុំមិនមានការៈទទួលខុសត្រូវណាមួយឡើយ ប្រសិនបើមានការទាមទារសំណងដែលភ្ជាប់ទៅនឹងកិច្ចព្រមព្រៀងផ្សេង (រវាងអ្នកត្រូវបានធានារ៉ាប់រងជាមួយនឹងបុគ្គលណាម្នាក់)។

ញ. ហានិភ័យនៃនុយក្លេអ៊ែរ

ទំនាក់ទំនង២៤ម៉ោង
全天候理赔团队 | 24/7 CALL CENTER
+855 78 24 24 24 / +855 87 24 24 24
អគារលេខដីឡូតិ៍, ផ្លូវលេខ១៦៩ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
BUILDING # LAND LOT C, ST. 169, PHUM 12, SANGKAT VEAL VONG,
KHAN 7 MAKARA, PHNOM PENH, KINGDOM OF CAMBODIA.

ការបាត់បង់ ឬការខូចខាតដាយថាហេតុណាមួយមិនថាកើតឡើងដោយផ្ទាល់ ឬដោយប្រយោល បណ្តាលមកពី ឬរួមចំណែកមកពី ឬកើតឡើងមកពីសារធាតុវិទ្យុសកម្មអ៊ីយ៉ូដ ឬការចម្លងរោគ ដោយសកម្មភាពវិទ្យុសកម្ម មកពីឥន្ធនៈនុយក្លេអ៊ែរ ឬមកពីសំណល់នុយក្លេអ៊ែរដែលមកពីចំហេះនុយក្លេអ៊ែរ។

ដ. ខសន្យា បញ្ជាក់អះអាងផ្នែកព័ត៌មានវិទ្យា

ការខូចខាតចំពោះទ្រព្យសម្បត្តិ ត្រូវបានធានារ៉ាប់រងនៅក្រោមកិច្ចសន្យាធានារ៉ាប់រងនេះ មានន័យថាជាការខូចខាតនៃរូបរាង ចំពោះលក្ខណៈនៃទ្រព្យសម្បត្តិត្រូវបានធានារ៉ាប់រង។ ការខូចខាតផ្នែករូបរាងចំពោះលក្ខណៈនៃទ្រព្យសម្បត្តិ ត្រូវបានធានារ៉ាប់រងនឹងមិនត្រូវរួមបញ្ចូលការខូចខាតទិន្នន័យ ឬសូហ្វវែរ ជាពិសេសការផ្លាស់ប្តូរដែលប៉ះពាល់ដល់ទិន្នន័យ សូហ្វវែរ ឬកម្មវិធីកុំព្យូទ័រដែលកើតមានដោយសារការលុប ឬការផ្លាស់ប្តូរទ្រង់ទ្រាយខុសពីរចនាសម្ព័ន្ធដើម។

ជាលទ្ធផល កិច្ចសន្យាធានារ៉ាប់រងនេះមិនរួមបញ្ចូលនូវចំណុចដូចខាងក្រោម៖

- ការបាត់បង់ ឬការខូចខាតទិន្នន័យ ឬ សូហ្វវែរ ជាពិសេសការផ្លាស់ប្តូរដែលប៉ះពាល់ដល់ទិន្នន័យសូហ្វវែរ ឬកម្មវិធីកុំព្យូទ័រដែលកើតមានដោយសារការលុប ឬការផ្លាស់ប្តូរទ្រង់ទ្រាយខុសពីរចនាសម្ព័ន្ធដើម និងការបាត់បង់ដោយការផ្អាកអាជីវកម្មណាមួយបណ្តាលមកពីការបាត់បង់ និងការខូចខាតបែបនេះ។ ទោះបីជានេះជាករណីមិនធានាក៏ដោយ ការបាត់បង់ ឬការខូចខាតទិន្នន័យ ឬ សូហ្វវែរ ដែលជាលទ្ធផលផ្ទាល់នៃការខូចខាតផ្នែករូបរាង ចំពោះលក្ខណៈនៃទ្រព្យសម្បត្តិត្រូវបានធានារ៉ាប់រងនោះនឹងត្រូវបានធានា។

- ការបាត់បង់ ឬការខូចខាត ដោយសារភាពមិនប្រក្រតីនៃតួនាទីលទ្ធភាពទំហំនៃការប្រើប្រាស់ ឬលទ្ធភាពក្នុងការចូលទៅក្នុងទិន្នន័យ សូហ្វវែរ ឬកម្មវិធីកុំព្យូទ័រ និងការបាត់បង់ដោយការផ្អាកអាជីវកម្មបណ្តាលមកពីការបាត់បង់ ឬខូចខាតទិន្នន័យទាំងនេះ។

ហ. ករណីមិនធានាលើសកម្មភាពគេវកម្ម

ទោះបីជាមានបទប្បញ្ញត្តិណាមួយផ្ទុយទៅនឹងកិច្ចសន្យាធានារ៉ាប់រងនេះ ឬបដ្ឋិលេខបន្ថែមណាមួយក៏ដោយ កិច្ចសន្យាធានារ៉ាប់រងនេះមិនរួមបញ្ចូល ការបាត់បង់ ការខូចខាត សោហ៊ុយ ឬចំណាយក្នុងទម្រង់ណាមួយដែលត្រូវបានបង្កឡើងដោយផ្ទាល់ ឬដោយប្រយោលដែល

ទំនាក់ទំនង២៤ម៉ោង
全天候理赔团队 | 24/7 CALL CENTER
+855 78 24 24 24 / +855 87 24 24 24
អគារលេខដីឡូតិ៍, ផ្លូវលេខ១៦៩ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
BUILDING # LAND LOT C, ST. 169, PHUM 12, SANGKAT VEAL VONG,
KHAN 7 MAKARA, PHNOM PENH, KINGDOM OF CAMBODIA.

បណ្តាលមកពី ឬពាក់ព័ន្ធនឹងសកម្មភាពភេរវកម្មណាមួយដោយមិនគិតពីបុព្វហេតុ ឬព្រឹត្តិការណ៍ណាមួយផ្សេងទៀតដែលរួមចំណែករួមគ្នា ឬជាលទ្ធផលបង្កឲ្យមានការបាត់បង់នោះ។

សម្រាប់គោលបំណងនៃខសន្យានេះ សកម្មភាពភេរវកម្មសំដៅលើសកម្មភាពមួយដែលរួមមានជាអាទិ៍ដូចជា ការប្រើកម្លាំង ឬអំពើហិង្សា និង/ឬ ការគំរាមកំហែង របស់បុគ្គលណាមួយ ឬក្រុមណាមួយ ទោះបីជាប្រព្រឹត្តិតែម្នាក់ឯង ឬក្នុងនាម ឬពាក់ព័ន្ធនឹងអង្គភាពណាមួយ ឬរដ្ឋាភិបាលក្នុងគោលបំណងនយោបាយ សាសនា មនោគមវិជ្ជា ឬគោលបំណងស្រដៀងគ្នានេះ ដែលរួមមានចេតនាប្រើឥទ្ធិពលលើរដ្ឋាភិបាលណាមួយ និង/ឬ បង្កការភ័យខ្លាចដល់សាធារណជន ឬក្រុមណាមួយនៃសាធារណជននោះ។

ខសន្យានេះ ក៏មិនរួមបញ្ចូលនូវការបាត់បង់ ការខូចខាត សោហ៊ុយ ឬ ចំណាយទម្រង់ណាមួយដែលត្រូវបានបង្កឡើងដោយផ្ទាល់ ឬប្រយោលដែល បណ្តាលមកពី ឬពាក់ព័ន្ធនឹងការចាត់វិធានការណាមួយដើម្បីគ្រប់គ្រង ទប់ស្កាត់ ឬទាក់ទងនឹងសកម្មភាពភេរវកម្មតាមវិធីណាមួយ។

ប្រសិនបើក្រុមហ៊ុនចោទប្រកាន់ថា តាមរយៈហេតុផលនៃករណីមិនធានានេះ ការបាត់បង់ ការខូចខាត សោហ៊ុយ ឬការចំណាយណាមួយ មិនត្រូវបានធានារ៉ាប់រងដោយបណ្ណសន្យារ៉ាប់រងនេះ នោះអ្នកត្រូវបានធានារ៉ាប់រងត្រូវទទួលបន្ទុកក្នុងការបញ្ជាក់ពីហេតុដែលផ្ទុយពីនេះ។

ផ្នែកទី ៧៖ ទីតាំងភូមិសាស្ត្រនៃការធានា

ដោយផ្អែកលើខចែង និងលក្ខខណ្ឌនៃកិច្ចសន្យាធានារ៉ាប់រងនេះ ក្រុមហ៊ុននឹងធានាទៅលើកម្មវត្ថុនៃការធានារ៉ាប់រងដែលស្ថិតនៅក្នុង ព្រះរាជាណាចក្រកម្ពុជា។

ផ្នែកទី ៨៖ លក្ខណៈសម្បត្តិនៃអ្នកឧទ្ធរណ៍

អ្នកទទួលផល ឬអ្នកទទួលសំណងធានារ៉ាប់រងអាចជាម្ចាស់បណ្ណសន្យារ៉ាប់រង និង/ឬ ភាគី ម្ចាស់បំណុលដែលជាស្ថាប័នហិរញ្ញវត្ថុស្របច្បាប់ ក្នុងករណីយានយន្តដែលបានដាក់ធានា រ៉ាប់រងពាក់ព័ន្ធកម្ចីតែប៉ុណ្ណោះ ដែលមានសិទ្ធិក្នុងការទទួលផល ឬសំណងពីក្រុមហ៊ុនយើងខ្ញុំ ដោយគោរពតាមបញ្ញត្តិ និងលក្ខខណ្ឌនានា ដូចមានចែងនៅក្នុងបណ្ណសន្យារ៉ាប់រងនេះ។

24/7
ទំនាក់ទំនង២៤ម៉ោង
全天候理赔团队 | 24/7 CALL CENTER
+855 78 24 24 24 / +855 87 24 24 24

អគារលេខដីឡូតិ៍, ផ្លូវលេខ១៦៩ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
BUILDING # LAND LOT C, ST. 169, PHUM 12, SANGKAT VEAL VONG,
KHAN 7 MAKARA, PHNOM PENH, KINGDOM OF CAMBODIA.

ផ្នែកទី ៩៖ ការកែប្រែកិច្ចសន្យាធានារ៉ាប់រង

រាល់ការកែប្រែ ឬការបន្ថែមលក្ខខណ្ឌណាមួយលើបណ្ណសន្យារ៉ាប់រងដើម គឺតម្រូវឱ្យភាគីទាំងសងខាងជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការកែប្រែ ឬបន្ថែមនេះតាមរយៈប្រព័ន្ធទំនាក់ទំនងអេឡិចត្រូនិច ឬផ្ញើជាលិខិតជូនដំណឹងទៅកាន់ភាគី ដែលត្រូវបានស្នើអោយមានការកែប្រែ ឬបន្ថែមនេះ។

បន្ទាប់ពីទទួលបានការជូនដំណឹងស្តីពីការកែប្រែ ឬបន្ថែមលក្ខខណ្ឌណាមួយពីម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកត្រូវបានធានារ៉ាប់រងហើយនោះ ក្រុមហ៊ុននឹងត្រួតពិនិត្យ ហើយជូនដំណឹងដល់ម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកត្រូវបានធានារ៉ាប់រង ចំពោះការយល់ព្រម ឬបដិសេធលើការស្នើសុំកែប្រែ ឬបន្ថែមលើបណ្ណសន្យារ៉ាប់រងនោះ ក្នុងរយៈពេលយ៉ាងយូរ ១០ (ដប់) ថ្ងៃនៃថ្ងៃធ្វើការ។

រាល់ការកែប្រែ ឬ បន្ថែមទាំងអស់នឹងមានសុពលភាព លុះត្រាតែមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរពីក្រុមហ៊ុនយើងខ្ញុំ និងមានចែងក្នុងបដ្ឋិលេខ។

ក្នុងករណីមានការខកខានមិនបានជូនដំណឹងអំពីការកែប្រែដូចបានរៀបរាប់ខាងលើ លក្ខខណ្ឌនៃកិច្ចសន្យាធានារ៉ាប់រងដើមនឹងត្រូវបានអនុវត្ត ហើយការទាមទារសំណង ដែលកើតឡើងដោយសារការកែប្រែនោះអាចនឹងត្រូវបានបដិសេធ។

ផ្នែកទី ១០៖ ការបន្តកិច្ចសន្យាធានារ៉ាប់រង

សុពលភាពនៃបណ្ណសន្យារ៉ាប់រង នឹងផុតកំណត់នៅកាលបរិច្ឆេទដូចដែលបានបញ្ជាក់នៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។ការស្នើសុំបន្តបណ្ណសន្យារ៉ាប់រង ត្រូវធ្វើឡើងឱ្យបានមុនកាលបរិច្ឆេទផុតសុពលភាព នៃបណ្ណសន្យារ៉ាប់រង។

រយៈពេលនៃការធានារ៉ាប់រង នឹងត្រូវបន្តស្របទៅតាមសេចក្តីណែនាំអំពីការបន្តរយៈពេលធានារ៉ាប់រង ដោយត្រូវបានចុះ ហត្ថលេខាដោយអ្នកត្រូវបានធានារ៉ាប់រង ឬអ្នកតំណាងឱ្យអ្នកត្រូវបានធានារ៉ាប់រង ឬភ្នាក់ងារដើងសាធានារ៉ាប់រង និងត្រូវបានប្រគល់ជូនក្រុមហ៊ុន ឬទទួលដោយក្រុមហ៊ុនតាមរយៈលិខិតអនុសិដ្ឋ អ្នកនាំសំបុត្រ ឬលិខិតប្រគល់ដោយផ្ទាល់ ឬអ៊ីម៉ែល និងការយល់ព្រមជាលាយលក្ខណ៍អក្សរពីខាងក្រុមហ៊ុន។

24/7
ទំនាក់ទំនង២៤ម៉ោង
全天候理赔团队 | 24/7 CALL CENTER
+855 78 24 24 24 / +855 87 24 24 24

អគារលេខដីឡូតិ៍, ផ្លូវលេខ១៦៩ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
BUILDING # LAND LOT C, ST. 169, PHUM 12, SANGKAT VEAL VONG, KHAN 7 MAKARA, PHNOM PENH, KINGDOM OF CAMBODIA.

ផ្នែកទី ១១៖ ការបញ្ចប់កិច្ចសន្យាធានារ៉ាប់រង

ប្រសិនបើម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកត្រូវបានធានារ៉ាប់រងមានបំណងបញ្ចប់បណ្ណសន្យារ៉ាប់រងនេះ នោះម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកត្រូវបានធានារ៉ាប់រងត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកកាន់ក្រុមហ៊ុន ក្នុងអំឡុងពេល ១០ (ដប់) ថ្ងៃ មុនពេលដល់កាលបរិច្ឆេទកំណត់នៃការបញ្ចប់បណ្ណសន្យារ៉ាប់រង។ ក្នុងករណីដែលលិខិតស្នើសុំបញ្ចប់បណ្ណសន្យារ៉ាប់រងមិនបានភ្ជាប់មកជាមួយនូវឯកសារគ្រប់គ្រាន់ទេ នោះក្រុមហ៊ុននឹងជូនដំណឹងមកកាន់ម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកត្រូវបានធានារ៉ាប់រងអំពីចំណុចខ្វះខាត ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានលិខិតស្នើសុំបញ្ចប់បណ្ណសន្យារ៉ាប់រង ហើយក្រុមហ៊ុននឹងធ្វើការជូនដំណឹង អំពីការឆ្លើយតបទៅម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកត្រូវបានធានារ៉ាប់រង អំពីការយល់ព្រម ឬបដិសេធដោយមានមូលហេតុត្រឹមត្រូវ ជាលាយលក្ខណ៍អក្សរក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានលិខិតស្នើសុំបញ្ចប់បណ្ណសន្យារ៉ាប់រង និងឯកសារគ្រប់គ្រាន់។

ក្រុមហ៊ុននឹងបង្វិលប្រាក់ ត្រឡប់ទៅវិញក្នុងរយៈពេលយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃព្រមព្រៀងបញ្ចប់បណ្ណសន្យារ៉ាប់រង ប៉ុន្តែក្រុមហ៊ុនអាចនឹងស្នើរសុំពេលវេលាបន្ថែមក្នុងការបង្វិលប្រាក់ ដោយផ្អែកលើហេតុផលសមស្រប និងមានឯកភាពពី **ន.ធ.ក**។ ក្នុងករណីនេះផងដែរ ក្រុមហ៊ុននឹងបង្វិលត្រលប់ជូននូវចំនួន ៩០% (កៅសិប) ភាគរយនៃបុព្វលាភដែលនៅសល់។

ចំពោះករណីនៃការបញ្ចប់បណ្ណសន្យារ៉ាប់រងនេះ ប្រសិនបើមានការទាមទារសំណងណាមួយកើតឡើង ហើយខាងក្រុមហ៊ុនបានធ្វើការទូទាត់សំណងនោះរួចរាល់ នោះក្រុមហ៊ុននឹងមិនមានកាតព្វកិច្ចក្នុងការបង្វិលសងនូវបុព្វលាភសម្រាប់រយៈពេលនូវសល់នោះទេ។

ផ្នែកទី ១២៖ ការលុបចោលកិច្ចសន្យាធានារ៉ាប់រង

ក្រុមហ៊ុនរក្សាសិទ្ធិក្នុងការលុបចោលបណ្ណសន្យារ៉ាប់រង តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់អ្នកត្រូវបានធានារ៉ាប់រង ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ ក្នុងករណីដូចខាងក្រោម៖

- បុព្វលាភធានារ៉ាប់រងមិនត្រូវបានបង់ក្រោយរយៈពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីបណ្ណសន្យារ៉ាប់រងមានសុពលភាព។
- ក្រុមហ៊ុនរកឃើញថាម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកត្រូវបានធានារ៉ាប់រងមានការលាក់បាំងក្លែងបន្លំ និង/ឬ មិនបានបង្ហាញព័ត៌មានពិត។

ទំនាក់ទំនង២៤ម៉ោង
全天候理赔团队 | 24/7 CALL CENTER
+855 78 24 24 24 / +855 87 24 24 24
អគារលេខដីឡូតិ៍, ផ្លូវលេខ១៦៩ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
BUILDING # LAND LOT C, ST. 169, PHUM 12, SANGKAT VEAL VONG,
KHAN 7 MAKARA, PHNOM PENH, KINGDOM OF CAMBODIA.

ផ្នែកទី ១៣៖ ការទាមទារសំណង

បណ្ណសន្យារ៉ាប់រងនេះមានលក្ខខណ្ឌ និងនីតិវិធីសម្រាប់ទាមទារសំណងដូចខាងក្រោម៖

ចំណុច ក. លក្ខណៈសម្បត្តិរបស់អ្នកដាក់ពាក្យស្នើសុំទាមទារសំណង

កិច្ចសន្យាធានារ៉ាប់រងតម្រូវអោយអ្នកដាក់ពាក្យស្នើសុំទាមទារសំណង ត្រូវតែជាភាគីដែលស្របច្បាប់ដូចមានចែងក្នុងវិញ្ញាបនបត្រធានារ៉ាប់រង ឬសាច់ញាតិរបស់អ្នកត្រូវបានធានារ៉ាប់រងដែលមានឯកសារផ្លូវច្បាប់បញ្ជាក់ និងទទួលស្គាល់ពីអាជ្ញាធរពាក់ព័ន្ធ។

ចំណុចខ. នីតិវិធីនៃការផ្តល់ព័ត៌មាន

ក្នុងករណីមានហេតុការណ៍ណាមួយដែលនាំអោយមានបណ្តឹងទាមទារសំណងកើតឡើង អ្នកត្រូវបានធានារ៉ាប់រងត្រូវតែជូនដំណឹងមកក្រុមហ៊ុនជាបន្ទាន់ តាមរយៈទូរស័ព្ទបន្ទាន់ ២៤ម៉ោង ជាលាយលក្ខណ៍អក្សរ ឬអញ្ជើញមកកាន់ក្រុមហ៊ុនដោយផ្ទាល់ ដោយបញ្ជាក់ពីប្រភេទ និងទំហំនៃការបាត់បង់ ឬខូចខាត។

- ក្រុមហ៊ុននឹងឆ្លើយតបទៅកាន់អ្នកត្រូវបានធានារ៉ាប់រង ដើម្បីបញ្ជាក់នូវការជូនដំណឹងអំពីហានិភ័យដែលកើតឡើងតាមរយៈទូរស័ព្ទ ឬផ្ញើរសារតាមរយៈប្រព័ន្ធអេឡិចត្រូនិក ឬតាមរយៈលិខិតជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេលយ៉ាងយូរ ២៤ (ម្ភៃបួន)ម៉ោង បន្ទាប់ពីទទួលបានការជូនដំណឹង។
- ក្រុមហ៊ុននឹងផ្តល់ពាក្យស្នើសុំទាមទារសំណង តាមទម្រង់របស់ក្រុមហ៊ុន និងព្រមទាំងផ្តល់បញ្ជីឯកសារតម្រូវទៅកាន់អ្នកត្រូវបានធានារ៉ាប់រង ដែលទទួលរងការបាត់បង់ ឬការខូចខាតស្របតាមបណ្ណសន្យារ៉ាប់រង ក្នុងរយៈពេលយ៉ាងយូរ ២៤ (ម្ភៃបួន) ម៉ោង បន្ទាប់ពីទទួលបានការជូនដំណឹងអំពីហានិភ័យធានារ៉ាប់រង។

ចំណុចគ. ការផ្តល់ឯកសារ ឬភស្តុតាងក្នុងការទាមទារសំណង

នៅពេលដាក់ពាក្យទាមទារសំណងមកក្រុមហ៊ុនធានារ៉ាប់រង អ្នកត្រូវបានធានារ៉ាប់រងត្រូវផ្តល់ជូនក្រុមហ៊ុនធានារ៉ាប់រង នូវឯកសារដូចជា៖

ក. ទម្រង់ទាមទារសំណងដែលបានបំពេញ
ខ. ច្បាប់ចម្លងបណ្ណបើកបររបស់អ្នកបើកបរដែលមានសុពលភាព
គ. ច្បាប់ចម្លងបណ្ណសម្គាល់យានយន្ត
ឃ. ច្បាប់ចម្លងអត្តសញ្ញាណបណ្ណ
ង. ទម្រង់បែបបទផ្លូវការស្តីពីការពិនិត្យវិភាគ និងការវាយតម្លៃការជួសជុល
ច. ឯកសារពាក់ព័ន្ធផ្សេងៗ (ក្នុងករណីចាំបាច់)។

ក្នុងករណីដែលការស្នើសុំទាមទារសំណងធានារ៉ាប់រង មិនមានឯកសារគ្រប់គ្រាន់ ឬ ការបំពេញពាក្យ

24/7
ទំនាក់ទំនង២៤ម៉ោង
全天候理赔团队 | 24/7 CALL CENTER
+855 78 24 24 24 / +855 87 24 24 24
អគារលេខដីឡូតិ៍, ផ្លូវលេខ១៦៩ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
BUILDING # LAND LOT C, ST. 169, PHUM 12, SANGKAT VEAL VONG,
KHAN 7 MAKARA, PHNOM PENH, KINGDOM OF CAMBODIA.

ស្នើសុំទាមទារសំណងមិនបានត្រឹមត្រូវ ក្រុមហ៊ុននឹងជូនដំណឹងជាលាយលក្ខណ៍អក្សរ ឬតាមរយៈសារអេឡិចត្រូនិក ដោយបញ្ជាក់ឲ្យបានច្បាស់លាស់អំពីចំណុចខ្វះខាត ដល់អ្នកទាមទារសំណងក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទដែលក្រុមហ៊ុនទទួលបានការស្នើសុំទាមទារសំណង។

ចំណុចយ. រយៈពេលអតិបរមានៃការដោះស្រាយ និងទូទាត់សំណងជូនអតិថិជន

រាល់ឯកសារសំខាន់ក៏ដូចជាព័ត៌មាន និង ភស្តុតាងតម្រូវត្រូវតែផ្តល់អោយនាយកដ្ឋានដោះស្រាយសំណងជាចាំបាច់អោយបានឆាប់រហ័សបន្ទាប់ពីគ្រោះថ្នាក់ ឬការខូចខាតបានកើតឡើង។

ក្រុមហ៊ុននឹងធ្វើការឆ្លើយតបទៅកាន់អ្នកទាមទារសំណង អំពីការបដិសេធ ឬ ការសម្រេចផ្តល់សំណងជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេលយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីកាលបរិច្ឆេទដែលក្រុមហ៊ុនបានទទួលការស្នើសុំទាមទារសំណង និងឯកសារតម្រូវគ្រប់គ្រាន់។

ក្រុមហ៊ុន **អង្គរ ជេនេរ៉ាល អ៊ិនសួរេន ម.ក** នឹងធ្វើការទូទាត់សំណងជូនអ្នកដាក់ពាក្យស្នើសុំទាមទារសំណងតាមកាលកំណត់ដូចខាងក្រោម៖

- ក្នុងរយៈពេល៣ (បី) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីអ្នកដាក់ពាក្យស្នើសុំទាមទារសំណងបានឯកភាពយកសំណងជានាវ៉ាប់រង ចំពោះការទូទាត់សំណងទាំងស្រុង ឬ
- ក្នុងរយៈពេលដូចបានកំណត់ក្នុងកិច្ចព្រមព្រៀងទទួលយកសំណងជានាវ៉ាប់រងរវាងក្រុមហ៊ុន **អង្គរ ជេនេរ៉ាល អ៊ិនសួរេន** និងអ្នកដាក់ពាក្យស្នើសុំទាមទារសំណង ចំពោះការទូទាត់សំណងជានាវ៉ាប់រងជាដំណាក់កាល។

ការធ្វើសំណងនឹងត្រូវទូទាត់តាមរយៈ មូលប្បទានបត្រ និង/ឬ ផ្ទេរពីគណនីធនាគាររបស់ក្រុមហ៊ុន **អង្គរ ជេនេរ៉ាល អ៊ិនសួរេន ម.ក។**

ផ្នែកទី ១៤៖ ការរក្សាព័ត៌មានសម្ងាត់

រាល់ព័ត៌មានដែលបានផ្តល់ជូនក្រុមហ៊ុន នឹងត្រូវរក្សាជាព័ត៌មានសម្ងាត់ ហើយគ្មានព័ត៌មានផ្ទាល់ខ្លួនណាមួយនឹងត្រូវបញ្ចេញទៅឲ្យភាគីទីបីដោយគ្មានការយល់ព្រមជាមុនឡើយ លើកលែងតែបានតម្រូវ ឬអនុញ្ញាតឲ្យដោយច្បាប់ឬបទប្បញ្ញត្តិជាធរមាន។

24/7
ទំនាក់ទំនង២៤ម៉ោង
全天候理赔团队 | 24/7 CALL CENTER
+855 78 24 24 24 / +855 87 24 24 24

អគារលេខដីឡូតិ៍, ផ្លូវលេខ១៦៥ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
BUILDING # LAND LOT C, ST. 169, PHUM 12, SANGKAT VEAL VONG,
KHAN 7 MAKARA, PHNOM PENH, KINGDOM OF CAMBODIA.

ផ្នែកទី ១៥៖ នីតិវិធីនៃការផ្សះផ្សាទំនាស

ចំពោះគ្រប់វិវាទនៃកិច្ចសន្យាធានារ៉ាប់រងនេះដែលពាក់ព័ន្ធនឹងអាជីវកម្មធានារ៉ាប់រងភាគីណា មួយនៃភាគីវិវាទអាចនាំយកវិវាទទៅជូន **និយ័តករធានារ៉ាប់រងកម្ពុជា** ដើម្បីសម្រុះសម្រួលធ្វើការផ្សះផ្សាវិវាទមុននឹងប្តឹងទៅវេទិកាមជ្ឈត្តកម្ម ឬតុលាការមានសមត្ថកិច្ចលើកលែងតែរឿងព្រហ្មទណ្ឌ។

ផ្នែកទី ១៦៖ ច្បាប់និងយុត្តាធិការ

បណ្ណសន្យារ៉ាប់រងនេះត្រូវស្ថិតក្រោម និងបកស្រាយតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ ដែនយុត្តាធិការគឺស្របតាមច្បាប់តុលាការនៃព្រះរាជាណាចក្រកម្ពុជា។

ផ្នែកទី ១៧៖ លក្ខខណ្ឌទូទៅ

១៧.១. ច្បាប់អភិបាលកិច្ច

កិច្ចសន្យាធានារ៉ាប់រងនេះត្រូវបានបកស្រាយ ហើយរាល់វិវាទណាមួយទាក់ទិននឹងកិច្ចសន្យាធានារ៉ាប់រងនេះនឹងត្រូវបានកំណត់ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

១៧.២. ការផ្ទេរសិទ្ធិក្នុងការទាមទារសំណង

យើងខ្ញុំមានសិទ្ធិក្នុងការប្រើប្រាស់សោហ៊ុយ និងការចំណាយរបស់ខ្លួនចំពោះមធ្យោបាយសម្រាប់ការការពារក្តី ឬការដោះស្រាយនៃសំណងណាមួយ ឬការសម្រាច់ចិត្តណាមួយ ក្នុងនាមជាអ្នកត្រូវបានធានារ៉ាប់រង សម្រាប់ផលប្រយោជន៍របស់យើងខ្ញុំនៃការទាមទារសំណងណាមួយ ឬការខូចខាតណាមួយផ្សេងទៀត។ យើងខ្ញុំមានសិទ្ធិក្នុងការធ្វើដំណើរការនៃនិតិវិធីណាមួយ និងក្នុងការដោះស្រាយសំណងណាមួយ ហើយអ្នកត្រូវបានធានារ៉ាប់រងត្រូវផ្តល់ព័ត៌មាននិងជំនួយសមហេតុផលទាំងអស់សម្រាប់គោលបំណងនោះដូចដែលយើងខ្ញុំនឹងតម្រូវ។

១៧.៣. កិច្ចសន្យាធានារ៉ាប់រងស្ងួន

លោកអ្នកត្រូវផ្តល់មកឲ្យយើងខ្ញុំនូវការជូនដំណឹងជាលាយលក្ខណ៍អក្សរ ប្រសិនបើលោកអ្នកមានកិច្ចសន្យាធានារ៉ាប់រងស្ងួនណាមួយផ្សេងទៀតដែលធានាលើយានយន្តរបស់លោកអ្នក។ ប្រសិនបើនៅពេល

ទំនាក់ទំនង២៤ម៉ោង
全天候理赔团队 | 24/7 CALL CENTER
+855 78 24 24 24 / +855 87 24 24 24
អគារលេខដីឡូតិ៍, ផ្លូវលេខ១៦៥ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
BUILDING # LAND LOT C, ST. 169, PHUM 12, SANGKAT VEAL VONG,
KHAN 7 MAKARA, PHNOM PENH, KINGDOM OF CAMBODIA.

ដែលមានការទាមទារសំណងណាមួយកើតឡើងនៅក្រោមកិច្ចសន្យាធានារ៉ាប់រងនេះ ហើយមានកិច្ចសន្យាធានារ៉ាប់រងផ្សេងទៀតដែលធានាលើការបាត់បង់ ការខូចខាត ឬការៈទទួលខុសត្រូវដូចគ្នា យើងខ្ញុំនឹងធ្វើការទូទាត់ទៅតាមអត្រាសមាមាត្រនៃការបាត់បង់ ការខូចខាត សោហ៊ុយ ឬការចំណាយណាមួយតែប៉ុណ្ណោះ។ ប៉ុន្តែគ្មានអ្វីណាមួយនៅក្នុងខចែងនេះត្រូវបានដាក់បន្ទុកមកលើយើងខ្ញុំចំពោះការៈទទួលខុសត្រូវដែលយើងខ្ញុំមិនត្រូវបានអនុលោមនោះទេ។

១៧.៤. ករណីផ្សេងៗ

កិច្ចសន្យាធានារ៉ាប់រងនេះនឹងត្រូវអនុវត្តតែក្នុងករណីដែល៖

ក. បុគ្គលណាម្នាក់ដែលទាមទារសំណង បានអនុវត្តស្របតាមរាល់ ខចែង លក្ខខណ្ឌ បដ្ឋិលេខ ខសន្យា ឬការធានានៃកិច្ចសន្យាធានារ៉ាប់រងនេះ។

ខ. លោកអ្នកត្រូវប្រកាន់ភ្ជាប់នូវរាល់វិធានការសមស្របទាំងឡាយ ដើម្បីថែរក្សាទោចក្រយានយន្តរបស់លោកអ្នកឲ្យស្ថិតក្នុងស្ថានភាពដែលអាចបើបរបាន។

គ. លោកអ្នកបានចាត់វិធានការសមស្របទាំងឡាយដើម្បីរក្សាការពារទោចក្រយានយន្តរបស់លោកអ្នកពីការបាត់បង់ឬការខូចខាត។

ឃ. លោកអ្នកត្រូវអនុញ្ញាតឲ្យយើងខ្ញុំនូវពេលវេលាសមស្របណាមួយដើម្បីធ្វើការត្រួតពិនិត្យលើទោចក្រយានយន្តរបស់លោកអ្នក។

១៧.៥. សិទ្ធិទទួលបានការបញ្ចុះតម្លៃក្នុងករណីមិនមានការទាមទារសំណង

ប្រសិនបើពុំមានការទាមទារសំណងណាមួយត្រូវបានធ្វើឡើង ឬកើតឡើងពីកិច្ចសន្យាធានារ៉ាប់រងនេះ ហើយទោចក្រយានយន្តរបស់លោកអ្នកត្រូវបានធានារ៉ាប់រងដោយយើងខ្ញុំក្នុងរយៈពេល ១២ (ដប់ពីរ) ខែ បន្តបន្ទាប់គ្នាសម្រាប់ករណីដូចខាងក្រោម លោកអ្នកមានសិទ្ធិទទួលបានការបញ្ចុះតម្លៃនៅពេលបន្តកិច្ចសន្យាធានារ៉ាប់រងនៅឆ្នាំបន្ទាប់ដូចខាងក្រោម៖

រយៈពេលនៃការធានារ៉ាប់រង	ការបញ្ចុះតម្លៃ
បន្ទាប់ពីឆ្នាំទី ១ នៃការធានារ៉ាប់រង	១០%
បន្ទាប់ពីឆ្នាំទី ២ នៃការធានារ៉ាប់រង	១៥%
បន្ទាប់ពីឆ្នាំទី ៣ ឬច្រើនឆ្នាំ នៃការធានារ៉ាប់រង	២០%

ក្នុងករណីដែលមានការទាមទារសំណងធ្វើឡើងនៅពេលដែលការបញ្ចុះតម្លៃមានចំនួន ១៥% ឬ ២០% នោះការបញ្ចុះតម្លៃនឹងត្រូវកាត់បន្ថយមកត្រឹម ១០% ឬ ១៥% នៅពេលបន្តកិច្ចសន្យាធានារ៉ាប់រងនៅឆ្នាំបន្ទាប់។ ក្នុងករណីដែលមានការទាមទារសំណងធ្វើឡើងនៅពេលដែលការបញ្ចុះតម្លៃមានចំនួន ១០% ឬតិចជាងនេះ នោះការបញ្ចុះតម្លៃ ក្នុងករណីមិនមានការទាមទារសំណងទាំងអស់ត្រូវបញ្ចប់ នៅពេល

ទំនាក់ទំនង២៤ម៉ោង
全天候理赔团队 | 24/7 CALL CENTER
+855 78 24 24 24 / +855 87 24 24 24
អគារលេខដីឡូតិ៍, ផ្លូវលេខ១៦៩ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
BUILDING # LAND LOT C, ST. 169, PHUM 12, SANGKAT VEAL VONG,
KHAN 7 MAKARA, PHNOM PENH, KINGDOM OF CAMBODIA.

បន្តកិច្ចសន្យាធានារ៉ាប់រងនៅឆ្នាំបន្ទាប់។

ក្នុងករណីដែលមានការទាមទារសំណងច្រើនជាងមួយ នៅក្នុងរយៈពេលនៃការធានារ៉ាប់រងណាមួយ នោះការបញ្ចុះតម្លៃក្នុងករណីមិនមានការទាមទារសំណងទាំងអស់ត្រូវបញ្ចប់នៅពេលបន្តកិច្ចសន្យាធានារ៉ាប់រងនៅឆ្នាំបន្ទាប់ដោយមិនគិតពីភាគរយដែលលោកអ្នកធ្លាប់បានទទួលឡើយ។

ប្រសិនបើយើងខ្ញុំយល់ព្រមលើការផ្ទេរផលប្រយោជន៍នៅក្នុងកិច្ចសន្យាធានារ៉ាប់រងនេះ នៅពេលដែលផលប្រយោជន៍នៅក្នុងនាមរបស់លោកអ្នក នោះមិនត្រូវបានបន្ថែមផលប្រយោជន៍ដល់អ្នកថ្មីឡើយ។

ប្រសិនបើទោចក្រយានយន្តមានច្រើនជាងមួយដែលត្រូវបានពិពណ៌នានៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រង នោះការបញ្ចុះតម្លៃក្នុងករណីមិនមានការទាមទារសំណងត្រូវយកមកអនុវត្តប្រៀបដូចកិច្ចសន្យាធានារ៉ាប់រងដាច់ដោយឡែក ដែលទាក់ទងនឹងទោចក្រយានយន្តនីមួយៗ។

១៧.៦. មោឃភាពនៃបញ្ញត្តិមួយចំនួន និង សិទ្ធទាមទារសំណងមកវិញ

១. ក្នុងករណីដែលក្រុមហ៊ុនទទួលខុសត្រូវក្នុងការធ្វើសំណងទឹកប្រាក់ស្របតាមច្បាប់ ឬកិច្ចព្រមព្រៀងដែលក្រុមហ៊ុនមិនមានភារៈទទួលខុសត្រូវក្នុងការធ្វើសំណងធានារ៉ាប់រងនេះទេ នោះអ្នកត្រូវបានធានារ៉ាប់រងត្រូវសងទឹកប្រាក់ទាំងនោះមកក្រុមហ៊ុនវិញ។

២. ក្នុងករណីក្រុមហ៊ុនបានធ្វើសំណងចំពោះការទាមទារលើ ការខូចខាតយានយន្តរបស់អ្នកត្រូវបានធានារ៉ាប់រង ហើយព្រមទាំងបានធ្វើសំណងចំពោះការខូចខាតលើទ្រព្យសម្បត្តិរបស់តតិយជន លោកអ្នកត្រូវលះបង់ និង/ឬ ប្រគល់ទឹកប្រាក់ដែលក្រុមហ៊ុនបានធ្វើសំណងមកវិញ បើមិនដូចច្នោះទេក្រុមហ៊ុនមានសិទ្ធិប្តឹងទាមទារចំនួនទឹកប្រាក់នេះមកវិញព្រមទាំងសោហ៊ុយ ឬការចំណាយផ្សេងៗដែលកើតមានឡើង។

១៧.៧. ការគោរពតាមកាលកំណត់

ការគោរព និងអនុវត្តតាមយ៉ាងត្រឹមត្រូវនូវ ខចែង លក្ខខណ្ឌ និងបដ្ឋិលេខនៃកិច្ចសន្យាធានារ៉ាប់រងនេះ ដោយអ្នកត្រូវបានធានារ៉ាប់រងក្នុងកម្រិតដែលមានការពាក់ព័ន្ធនឹងចំណុចដែលខ្លួនត្រូវធ្វើ ឬគោរពតាមហើយភាពពិតប្រាកដនៃសេចក្តីប្រកាសអះអាង និងចម្លើយនៅលើកម្រងសំណួរ និងបែបបទស្នើសុំធានារ៉ាប់រងដែលបានធ្វើឡើងគឺជាលក្ខខណ្ឌជាមុននៃការទទួលខុសត្រូវរបស់ក្រុមហ៊ុនក្នុងការធ្វើសំណងយោងតាមកិច្ចសន្យាធានារ៉ាប់រងនេះ។

១៧.៨. អត្ថន័យ

បណ្ណសន្យារ៉ាប់រងនេះ និងវិញ្ញាបនបត្រធានារ៉ាប់រង (ដែលបង្កើតបានជាផ្នែកមួយនៃកិច្ចសន្យាធានារ៉ាប់រង) ត្រូវអានជាមួយគ្នាជាកិច្ចសន្យាតែមួយ ហើយពាក្យពេចន៍ និងវាក្យសព្ទដែលមានអត្ថន័យជាក់

24/7
ទំនាក់ទំនង២៤ម៉ោង
全天候理赔团队 | 24/7 CALL CENTER
+855 78 24 24 24 / +855 87 24 24 24
អគារលេខដីឡូតិ៍, ផ្លូវលេខ១៦៩ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
BUILDING # LAND LOT C, ST. 169, PHUM 12, SANGKAT VEAL VONG,
KHAN 7 MAKARA, PHNOM PENH, KINGDOM OF CAMBODIA.

លាក់ ស្ថិតនៅក្នុងផ្នែកណាមួយនៃបណ្ណសន្យារ៉ាប់រងនេះ ឬវិញ្ញាបនបត្រធានារ៉ាប់រងត្រូវមានអត្ថន័យដាក់លាក់ដូចគ្នា ទោះជាប្រើនៅចំណុចណាក៏ដោយ។

១៧.៩. ស្វ័យភាពនៃបញ្ញត្តិ

ក្នុងករណីដែល ខចែង ឬលក្ខខណ្ឌណាមួយនៃកិច្ចសន្យាធានារ៉ាប់រងត្រូវបានរកឃើញថាមិនមានសុពលភាព ឬមិនអាចអនុវត្តបាននោះ ខចែង ឬលក្ខខណ្ឌផ្សេងៗទៀតដែលមិនប៉ះពាល់ត្រូវ មានសុពលភាព និងមានប្រសិទ្ធិភាព។

១៧.១០. កិច្ចព្រមព្រៀងលើការបង់រំលស់

បានយល់ និងព្រមព្រៀងថា ក្រុមហ៊ុនហរិញ្ញវត្ថុដែលមានឈ្មោះនៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រងនៃកិច្ចសន្យាធានារ៉ាប់រងនេះ (តទៅនេះហៅថា ម្ចាស់) គឺជាម្ចាស់នៃទោចក្រយានយន្តហើយបានយល់ និងព្រមព្រៀងថាទោចក្រយានយន្តគឺត្រូវបានចាត់ទុកថាជាកិច្ចព្រមព្រៀងលើការបង់រំលស់ដែលត្រូវបានធ្វើឡើងរវាងម្ចាស់មួយផ្នែក និងអ្នកត្រូវបានធានារ៉ាប់រងជាម្ចាស់មួយផ្នែកទៀត។ បានយល់ និងព្រមព្រៀងបន្ថែមទៀតថា ការទូទាត់ដែលធ្វើឡើងទាក់ទងនឹង ការបាត់បង់ ឬការខូចខាត (ដែលការបាត់បង់ ឬការខូចខាតនោះមិនត្រូវបានធ្វើឲ្យប្រសើរដោយការជួសជុល ការធ្វើឲ្យដូចដើមវិញ ឬការជំនួស) ក្រោមផ្នែក ក នៃកិច្ចសន្យាធានារ៉ាប់រងនេះ នឹងត្រូវធ្វើសំណងឲ្យទៅម្ចាស់ដរាបណាពួកគេជាម្ចាស់ទោចក្រយានយន្ត នោះ ហើយការទទួលយកសំណងនេះនឹងក្លាយជាការដោះស្រាយសំណងពេញលេញ និងចុងក្រោយរបស់ក្រុមហ៊ុនទាក់ទងនឹងការបាត់បង់ និងការខូចខាត។

បានយល់ និងព្រមព្រៀងថា ទោះបីជាបទប្បញ្ញត្តិណាមួយនៅក្នុងកិច្ចព្រមព្រៀងលើការបង់រំលស់នេះផ្ទុយក៏ដោយកិច្ចសន្យាធានារ៉ាប់រងនេះ គឺត្រូវបានចេញទៅឲ្យអ្នកត្រូវបានធានារ៉ាប់រងដែលមានឈ្មោះនៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រង ជាភាគីចំបង និងមិនមែនជាភ្នាក់ងារ ឬអ្នកទទួលយកការគ្រប់គ្រងលើទ្រព្យសម្បត្តិសម្រាប់ម្ចាស់ និងគ្មានអ្វីនឹងត្រូវបានបកស្រាយថាចាត់ទុកអ្នកត្រូវបានធានារ៉ាប់រង ជាភ្នាក់ងារ ឬអ្នកទទួលយកការគ្រប់គ្រងលើទ្រព្យសម្បត្តិសម្រាប់ម្ចាស់ ឬជាការងារចាត់តាំង (ថាតើទាក់ទងនឹងផ្លូវច្បាប់ ឬសមធម៌) ដោយអ្នកត្រូវបានធានារ៉ាប់រង ទៅឲ្យម្ចាស់តាមសិទ្ធិរបស់ខ្លួននូវអត្ថប្រយោជន៍ និងការទាមទារសំណងក្រោមកិច្ចសន្យាធានារ៉ាប់រងនេះ។ បានយល់ និងព្រមព្រៀងជាចុងក្រោយថា អ្នកត្រូវបានធានារ៉ាប់រងមិនអាចបែងចែកអត្ថប្រយោជន៍ និងការទាមទារសំណងក្រោមកិច្ចសន្យាធានារ៉ាប់រងនេះដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីក្រុមហ៊ុនបានឡើយ។

រាល់ខចែង និងលក្ខខណ្ឌទាំងអស់ត្រូវផ្អែកលើកិច្ចសន្យាធានារ៉ាប់រងនេះ។

ទំនាក់ទំនង២៤ម៉ោង
全天候理赔团队 | 24/7 CALL CENTER
+855 78 24 24 24 / +855 87 24 24 24
អគារលេខដីឡូតិ៍, ផ្លូវលេខ១៦៩ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
BUILDING # LAND LOT C, ST. 169, PHUM 12, SANGKAT VEAL VONG,
KHAN 7 MAKARA, PHNOM PENH, KINGDOM OF CAMBODIA.

ផ្នែកទី ១៨៖ នីតិវិធីប្តឹងតវ៉ា

អនុវត្តចំពោះគ្រប់ចំណុចធានាទាំងអស់

ក្រុមហ៊ុនប្តេជ្ញាក្នុងការផ្តល់សេវាកម្មដ៏ប្រសើរបំផុត ប្រសិនបើអតិថិជនមានការមិនពេញចិត្ត ក្រុមហ៊ុននឹងខិតខំស្វែងរកដំណោះស្រាយភ្លាម ប៉ុន្តែប្រសិនបើក្រុមហ៊ុនមិនអាចដោះស្រាយ បញ្ហាបាន ក្រុមហ៊ុននឹងជូនដំណឹងទៅអតិថិជនក្នុងអំឡុងពេល ៤៨ ម៉ោង ហើយនឹងខិតខំប្រឹង ប្រែងរកដំណោះស្រាយឱ្យអតិថិជនក្នុងអំឡុងពេល ៤ សប្តាហ៍ ប្រសិនបើក្រុមហ៊ុននៅតែមិនអាចផ្តល់ដំណោះស្រាយជូនអតិថិជន ក្រុមហ៊ុននឹងជូនដំណឹងដល់អតិថិជននូវរយៈពេលជាក់លាក់មួយដែលក្រុមហ៊ុនអាចរកដំណោះស្រាយជូនអតិថិជនបាន។

ប្រសិនបើអតិថិជនត្រូវការប្តឹងតវ៉ាមិនពេញចិត្ត សូមធ្វើការទំនាក់ទំនងតាមរយៈ៖

ក្រុមការងារបម្រើសេវាកម្មអតិថិជនរបស់ក្រុមហ៊ុន៖

ការិយាល័យកណ្តាល របស់ អង្គរ ជេនេរ៉ាល អ៊ិនសួរេន ម.ក
អគារលេខ ដីឡូត៍ C ផ្លូវលេខ ១៦៩ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ
៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ៖ (+855)78 242 424
អ៊ីម៉ែល៖ customerservice@agi.com.kh

ប្រសិនបើក្រុមហ៊ុនមិនអាចរកដំណោះស្រាយលើបណ្តឹងតវ៉ា ក្នុងរយៈពេល ១២សប្តាហ៍ អ្នកត្រូវបានធានារ៉ាប់រងអាចបន្តប្តឹងទៅ៖

និយ័តករធានារ៉ាប់រងកម្ពុជា
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
អគារលេខ ១៦៨F (ជាន់ទី៦) ផ្លូវ៥៩៨
សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ផ្នែកទី ១៩: ព័ត៌មានទំនាក់ទំនង

សូមទំនាក់ទំនងក្រុមហ៊ុនតាមរយៈ៖

អង្គរ ជេនេរ៉ាល អ៊ិនសួរេន ម.ក

អគារលេខ ដីឡូត៍ C ផ្លូវលេខ ១៦៩ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ
៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

នាយកដ្ឋានបម្រើសេវាកម្មអតិថិជន

ទូរស័ព្ទលេខ៖(+855)78 242 424

អ៊ីម៉ែល៖ customerservice@agi.com.kh

នាយកដ្ឋានដោះស្រាយសំណង (២៤/៧)

ទូរស័ព្ទលេខ៖1800 20 24 24

អ៊ីម៉ែល៖ claims@agi.com.kh